មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

ខែមិថុនា ឆ្នាំ២០១៤

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា

# ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍




USAID
ជំនួយពីប្រជាជនអាមេរិក

EAST . WEST MANAGEMENT INSTITUTE
Program on Rights and Justice (PRAJ)

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

របាយការណ៍ស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា" ជាលទ្ធផលនៃការអនុវត្តន៍គម្រោងសង្កេតការណ៍សវនាការ របស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។ ចក្ខុវិស័យរបស់ ម.ស.ម.ក គឺកម្ពុជាជាព្រះរាជាណាចក្រមួយគ្មានអំពើហិង្សា ដែលក្នុងនោះប្រជាពលរដ្ឋទទួលបានសិទ្ធិជាមូលដ្ឋានមានសិទ្ធិស្មើគ្នា និងទទួលបានអំណាច ដើម្បីចូលរួមក្នុងលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍន៍ប្រទេស។ ម.ស.ម.ក មានគោលបំណងចង់បាននីតិរដ្ឋ ជាជាងនិទណ្ឌភាព ស្ថាប័នរឹងមាំ ជាជាងបុគ្គលខ្លាំង និងចង់បានសង្គមសេរីពហុបក្ស ដែលក្នុងនោះភាពចម្រុះត្រូវបានគេទទួលយក និងសាទរ ជាជាងព្រងើយកន្តើយ ឬដាក់ទណ្ឌកម្ម។ ស្លាកសញ្ញារបស់ ម.ស.ម.ក មានរូបព្រាប ស កំពុងហើរចេញពីរង្វង់មូលនៃផ្ទៃមេឃពណ៌ខៀវបញ្ជាក់អំពីការទាមទារសេរីភាពនៅកម្ពុជា។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ម.ស.ម.ក ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ ព្រមទាំងការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅទូទាំងប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទស្សនាគេហទំព័រ៖ www.cchrcambodia.org។

## សេចក្តីថ្លែងអំណរគុណ

របាយការណ៍នេះ កើតចេញពីកិច្ចឧបត្ថម្ភគាំទ្រ ដោយសប្បុរសអំពីសំណាក់ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក ("ជំនួយពីពលរដ្ឋអាមេរិក") និងវិទ្យាស្ថានគ្រប់គ្រងបូព៌ា បស្ចិមប្រទេស និងកិច្ចឧបត្ថម្ភគាំទ្រ ដោយសប្បុរសពីការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។ ខ្លឹមសារនៃរបាយការណ៍នេះ គឺជាការទទួលខុសត្រូវរបស់ ម.ស.ម.ក និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ជំនួយពីពលរដ្ឋអាមេរិក រដ្ឋាភិបាលសហរដ្ឋអាមេរិក ឬ វិទ្យាស្ថានគ្រប់គ្រងបូព៌ា បស្ចិម ឬ ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ។

## ចម្ងល់ និង មតិចូលរួម

ប្រសិនបើលោកអ្នកមានសំណួរ ឬចង់បានព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬប្រសិនបើលោកអ្នកចង់ផ្តល់យោបល់តប សូមផ្ញើអ៊ីម៉ែលមកកាន់ ម.ស.ម.ក តាមរយៈអាសយដ្ឋាន info@cchrcambodia.org។

របាយការណ៍នេះ និងការបោះពុម្ពផ្សាយផ្សេងៗរបស់ ម.ស.ម.ក អាចស្វែងរកបានតាមរយៈ www.cchrcambodia.org និងក៏អាចស្វែងរកបានផងដែរនៅលើគេហទំព័រសិទ្ធិមនុស្សកម្ពុជាដែលបង្ហោះដោយ ម.ស.ម.ក តាមរយៈ www.sithi.org។

ទិន្នន័យ ដែលបានសង្កេតទាំងអស់ក៏អាចស្វែងរកបាននៅលើប្រព័ន្ធគ្រប់គ្រងទិន្នន័យសង្កេតការណ៍សវនាការតាមរយៈ tmp.sithi.org ។ ព័ត៌មានបន្ថែម សូមទាក់ទងទូរសព្ទលេខ ៖ +៨៥៥ (0) ២៣៧២ ៦៩ ០១ ឬទូរសារ ៖ +៨៥៥ (0) ២៣ ៧២ ៦៩ ០២។

(cc) ២០១៤ ម.ស.ម.ក

ផ្ទះលេខ៧៩៨ ផ្លូវ៩៩ សង្កាត់បឹងត្របែក
ខណ្ឌចំការមន រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា

BY NC SA

# មាតិកា

**តារាងតួលេខ**

**អត្ថន័យ និងអក្សរកាត់** ........ i

**ខ្លឹមសារសង្ខេប** ........ iii

**១. សេចក្តីផ្តើម** ........ 1

១.១ .សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ........ 1

១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់អន្តរជាតិ ........ 1

១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់ជាតិ ........ 2

១.២ .គោលបំណង វិសាលភាព និង វិធីសាស្ត្រ ........ 3

**២. ទិន្នន័យ និង ការវាយតម្លៃលើការអនុវត្តន៍សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌** ........ 7

២.១ .សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលស្ថិតក្នុងសភាពគ្រោះថ្នាក់ ........ 8

២.១.១. សិទ្ធិទទួលបានសវនាការជាសាធារណៈ ........ 8

២.១.២. សិទ្ធិយល់ដឹងពីបទចោទប្រកាន់ ........ 10

២.១.៣. សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ ........ 13

២.១.៤. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........ 16

២.១.៥. សិទ្ធិបង្ហាញភស្តុតាង ........ 17

២.១.៦. សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ និងមានសម្អាងហេតុ ........ 19

២.១.៧. ឯករាជ្យភាព ភាពឥតលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រម ........ 21

២.១.៨. សវនាការទាក់ទិននឹងអនីតិជន ........ 24

២.២ .សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព ........ 27

២.២.១. សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី ........ 27

២.២.២. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាព ........ 27

២.២.៣. ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល ........ 28

២.២.៤. ការហាមឃាត់ប្រឆាំងនឹងការអនុវត្តន៍អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ........ 29

**៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍** ........ 30

៣.១ .អនុសាសន៍ដើម្បីធ្វើឲ្យប្រសើរឡើងនូវឯករាជ្យភាពរបស់តុលាការ ........ 31

៣.២ .អនុសាសន៍ទាក់ទងនឹងការពន្យល់ប្រាប់សិទ្ធិ.......31
៣.៣ .អនុសាសន៍ទាក់ទងនឹងសិទ្ធិមានវត្តមាននៅពេលសវនាការជំនុំជម្រះ.......31
៣.៤ .អនុសាសន៍ទាក់ទងនឹងសិទ្ធិមានមេធាវី.......32
៣.៥ .អនុសាសន៍ទាក់ទងនឹងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស.......32
៣.៦ .អនុសាសន៍ទាក់ទងនឹងភាពមិនលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រម.......32
៣.៧ .អនុសាសន៍ទាក់ទងនឹងសវនាការលើអនីតិជន.......33
**៤. គន្លងនិន្នាការ**.......35
នីតិអន្តរជាតិ.......35
នីតិជាតិ.......35
**៥. ឧបសម្ព័ន្ធ**.......38
តារាងសង្កេតការណ៍សវនាការ.......38

# តារាងតួលេខ


តួលេខទី១ (ក) ៖ សវនាការឧទ្ធរណ៍ដែលបានសង្កេត - បទឧក្រិដ្ឋ និងបទមជ្ឈិម ................ 7

តួលេខទី១ (ខ) ៖ សវនាការឧទ្ធរណ៍ដែលបានសង្កេត - ភាគីធ្វើបណ្ដឹងឧទ្ធរណ៍.................... 8

តួលេខទី២ ៖ សិទ្ធិទទួលបានសវនាការជាសាធារណៈ ..................................................... 9

តួលេខទី៣ ៖ សិទ្ធិយល់ដឹងពីបទចោទប្រកាន់ .............................................................. 11

តួលេខទី៤ ៖ ការពន្យល់ប្រាប់សិទ្ធិ.......................................................................... 12

តួលេខទី៥ ៖ សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ ..................................... 14

តួលេខទី៦៖ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស ........................................ 16

តួលេខទី៧ ៖ សាលដីការបស់សាលាឧទ្ធរណ៍ ............................................................... 20

តួលេខទី៨ ៖ សិទ្ធិទទួលបានសាលដីកាដោយមានសម្អាងហេតុច្បាស់លាស់ .................... 20

តួលេខទី៩ ៖ ភាពឥតលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រម ................................................ 24

# អត្ថន័យ និងអក្សរកាត់

| | |
|---|---|
| គណៈមេធាវី | គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា |
| កម្ពុជា | ព្រះរាជាណាចក្រកម្ពុជា |
| ម.ស.ម.ក | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា |
| ក្រមនីតិវិធីព្រហ្មទណ្ឌ | ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| តារាងសង្កេតការណ៍ | តារាងសង្កេតការណ៍ប្រើដោយអ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ដើម្បីកត់ត្រាទិន្នន័យសវនាការ នៅពេលសង្កេតការណ៍ |
| ការណែនាំអំពីតារាងសង្កេតការណ៍ | ឯកសារណែនាំលម្អិតដើម្បីជួយដល់អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ឲ្យមានការយល់ច្បាស់លាស់ចំពោះសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍។ |
| ក្រមសីលធម៌ | ឯកសារកំណត់អំពីកាតព្វកិច្ចនានានៃការមិនជ្រៀតជ្រែក គោលបំណងមិនលម្អៀង និងការសម្ងាត់ ដែលចងជាកាតព្វកិច្ចដល់អ្នកសង្កេតការណ៍របស់ ម.ស.ម.ក |
| រដ្ឋធម្មនុញ្ញ | រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា |
| សាលាឧទ្ធរណ៍ | សាលាឧទ្ធរណ៍រាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា |
| អ.ស.ក | អនុសញ្ញាស្តីពីសិទ្ធិកុមារ |
| ក្រមព្រហ្មទណ្ឌ | ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា |
| ប្រព័ន្ធគ្រប់គ្រងទិន្នន័យ | ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ដែលអ្នកសង្កេតការណ៍របស់ ម.ស.ម.ក រក្សាទុកទិន្នន័យសវនាការ ដែលបានកត់ត្រានៅលើតារាងសង្កេតការណ៍ |
| វ.គ.ប.ស | វិទ្យាស្ថានគ្រប់គ្រងបូព៌ា បស្ចិមប្រទេស |
| ក.អ.ស.ព.ន | កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ |
| ក្រ.ម | ក្រសួងមហាផ្ទៃ |
| ក្រ.យ | ក្រសួងយុត្តិធម៌ |
| ក្រ.ស.ក | ក្រសួងសង្គមកិច្ច |
| មិនពាក់ព័ន្ធ | ទិន្នន័យមិនពាក់ព័ន្ធ |
| អ.ម.រ | អង្គការមិនមែនរដ្ឋាភិបាល |
| ក.ស.ម.វ.ប | ការិយាល័យទទួលបន្ទុកសិទ្ធិមនុស្ស និងវិទ្យាស្ថានប្រជាធិបតេយ្យ |
| ការិយាល័យឧត្តមស្នងការ | ការិយាល័យឧត្តមស្នងការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ |
| អ.ស.ស.អ | អង្គការសម្រាប់សន្តិសុខ និងសហប្រតិបត្តិការនៅអឺរ៉ុប |
| គម្រោង | គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក |
| របាយការណ៍ | របាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា |
| អំឡុងពេលរបាយការណ៍ | ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣ ដល់ ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ |
| រដ្ឋាភិបាល | រាជរដ្ឋាភិបាលកម្ពុជា |
| យុទ្ធសាស្ត្រ | យុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៃរាជរដ្ឋាភិបាលកម្ពុជា |
| អ្នកសង្កេតការណ៍ | អ្នកសង្កេតការណ៍សវនាការរបស់ម.ស.ម.ក |
| ស.ស.ស.ម | សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស |
| អ.ស.ប | អង្គការសហប្រជាជាតិ |

| | |
|---|---|
| អ៊ុនតាក់ | អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា |
| ច្បាប់អ៊ុនតាក់ | បទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ឆ្នាំ១៩៩២ |
| ជំនួយពីពលរដ្ឋអាមេរិក | ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិនៃសហរដ្ឋអាមេរិក |

# ខ្លឹមសារសង្ខេប

ដំណើរការរបស់តុលាការស្ថិតក្នុងចំណោមបញ្ហាព្រួយបារម្ភនៃសិទ្ធិមនុស្សសំខាន់ៗនៅកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំ ហើយដែលជាបញ្ហាស្មុគស្មាញ ដោយសារតែតុលាការមានតួនាទីក្នុងការការពារ និងអនុវត្តសិទ្ធិដទៃទៀត ព្រមទាំងជាគ្រឹះនៃនីតិរដ្ឋ។ ទោះបីជាមានការវិវឌ្ឍន៍នឹងនរមួយចំនួននៅក្នុងការប្រកាន់ខ្ជាប់នីតិវិធីមួយចំនួន ដែលកំណត់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងតុលាការកម្ពុជាយ៉ាងណាក្តី ក៏បញ្ហាគួរឲ្យព្រួយបារម្ភមួយចំនួនទៀតនៅតែកើតមាន។ បញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗដែលប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា គឺកង្វះខាតប្រព័ន្ធនៃការបែងចែកអំណាច និងឥទ្ធិពលជាបន្តបន្ទាប់ ដែលអង្គនីតិប្រតិបត្តិប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនលើស្ថាប័នតុលាការ។

ក្រៅពីក្តីបារម្ភជារួមទាក់ទិននឹងកង្វះឯករាជ្យភាពរបស់តុលាការនៅកម្ពុជា បញ្ហាទាក់ទងនឹងសិទ្ធិទទួលបានសវនាការជាសាធារណៈ សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស គឺនៅតែជាបញ្ហាប្រឈមនៅឡើយនៅកម្ពុជា។ បន្ថែមពីលើនេះទៀត គុណភាពនៃភស្តុតាង ដែលបានបង្ហាញនៅពេលសវនាការ ជារឿយនៅមានកម្រិតទាប និងគំរាមកំហែងដល់សិទ្ធិត្រូវបានផ្តន្ទាទោសហួសពីវិមតិសង្ស័យ។

គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ("គម្រោង") ប្រមូលទិន្នន័យបានមកពីការសង្កេតការណ៍សវនាការព្រហ្មទណ្ឌចំនួន ២០៤ នៅសាលាឧទ្ធរណ៍ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៤ ("អំឡុងពេលរបាយការណ៍") ដើម្បីវាយតម្លៃអំពីការប្រកាន់ខ្ជាប់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់សាលាឧទ្ធរណ៍ ដូចដែលបានកំណត់នៅក្នុងច្បាប់ជាតិ និងច្បាប់អន្តរជាតិ។ របាយការណ៍នេះបង្ហាញ និងវិភាគទៅលើទិន្នន័យ ដែលប្រមូលបាននៅក្នុងអំឡុងពេលរបាយការណ៍។

**ជំពូកទី១ (សេចក្តីផ្តើម)** ពន្យល់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលជាសិទ្ធិមូលដ្ឋាន និងជាសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាសកល ព្រមទាំងផ្តល់នូវទិដ្ឋភាពសង្ខេបអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ពាក់ព័ន្ធ មុននឹងឈានដល់ការកំណត់ពីវិសាលភាព វិធីសាស្ត្រ និងគោលបំណងនៃរបាយការណ៍នេះ។

**ជំពូកទី២ (ទិន្នន័យ និងរបកគំហើញ)** បង្ហាញពីទិន្នន័យ ដែលប្រមូលបាននៅសាលាឧទ្ធរណ៍អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ពាក់ព័ន្ធ ដែលបានកំណត់មួយចំនួន និងធ្វើការវិភាគទិន្នន័យទាំងនោះក្នុងគោលបំណងកំណត់ពីនិន្នាការក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ភ្ជាប់ទៅនឹងលទ្ធផលនៃការវិភាគ ជំពូកនេះកំណត់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ណាដែលត្រូវគោរពបានល្អ និងសិទ្ធិដែលមិនទាន់ត្រូវបានគោរពនៅសាលាឧទ្ធរណ៍។

**ជំពូកទី៣ (សេចក្តីសន្និដ្ឋាន និងអនុសាសន៍)** ផ្តល់អនុសាសន៍មួយចំនួន ដែលត្រូវបានដាក់ចេញចំពោះអង្គភាព និងស្ថាប័នពាក់ព័ន្ធផ្សេងៗ រួមទាំងរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ក្រសួងយុត្តិធម៌

("ក្រ.ធ") អាជ្ញាធរអនុវត្តច្បាប់ អាជ្ញាធរពន្ធនាគារ ក៏ដូចជា អង្គការមិនមែនរដ្ឋាភិបាល ដែលជាប់ពាក់ព័ន្ធនឹងលទ្ធផលដែលបានរកឃើញនៅក្នុងរបាយការណ៍។

ម.ស.ម.ក សង្ឃឹមថា ទិន្នន័យ ការវិភាគ និងអនុសាសន៍ ដែលមាននៅក្នុងរបាយការណ៍នេះ នឹងជួយសម្រួលដល់ការបង្កើនការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជួយគាំទ្រដល់អ្នកទាំងឡាយណា ដែលធ្វើការដើម្បីជានានូវយុត្តិធម៌ និងសមភាពសម្រាប់មនុស្សគ្រប់រូបនៅក្នុងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

# ១. សេចក្តីផ្តើម

## ១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌បង្កើតបានជាធាតុផ្សំដ៏សំខាន់នៃនីតិរដ្ឋ និងការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាសិទ្ធិមូលដ្ឋាន និងជាសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាសកល ហើយដែលមានចែងនៅក្នុងច្បាប់អន្តរជាតិកម្រិតខ្ពស់បំផុត ដោយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ("ស.ស.ស.ម") និង កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ក៏ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ព្រមទាំងតាមរយៈបទប្បញ្ញត្តិជាក់លាក់មួយចំនួននៃច្បាប់ជាតិផងដែរ។

### ១.១.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់អន្តរជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ជាផ្នែកដ៏សំខាន់នៃប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ហើយសិទ្ធិនេះផ្តល់ឲ្យបុគ្គលគ្រប់រូបដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ត្រូវបានប្រព្រឹត្តដោយយុត្តិធម៌ និងស្មើភាពគ្នា នៅខណៈរដ្ឋកំណត់អំពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់អ្នកទាំងនោះ។ នៅពេលដែលអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ឲ្យបានត្រឹមត្រូវ វានឹងការពារដល់សិទ្ធិរបស់ជនជាប់ចោទ និងជនរងគ្រោះ ព្រមទាំងធានានូវការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវ។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ រួមផ្សំដោយសិទ្ធិជាក់លាក់ផ្សេងៗមួយចំនួន ដែលបញ្ចូលនៅក្នុងនីតិវិធីច្បាប់ទាំងមូល ដោយគិតចាប់ពីដំណាក់កាលដំបូងនៃការចាប់ខ្លួនជនសង្ស័យ រហូតដល់ការបញ្ចប់បណ្តឹងឧបាស្រ័យ។

**មាត្រា ១០ នៃ ស.ស.ស.ម**

មនុស្សគ្រប់រូប មានសិទ្ធិស្មើគ្នាពេញលេញ សុំឲ្យតុលាការឯករាជ្យ និងមិនលម្អៀង ពិនិត្យរឿងក្តីរបស់ខ្លួនជាសាធារណៈ និងដោយសមធម៌ ដើម្បីសម្រេចលើសិទ្ធិ កាតព្វកិច្ច និងភាពសមហេតុផលចំពោះការចោទប្រកាន់ទាំងឡាយខាងបទព្រហ្មទណ្ឌ។

ស.ស.ស.ម[1] និង ក.អ.ស.ព.ន[2] ធានាសិទ្ធិទទួលបានសវនាការយុត្តិធម៌ និងជាសាធារណៈ ដោយសាលាជម្រះក្តីឯករាជ្យ និងឥតលម្អៀង។ ក.អ.ស.ព.ន បង្កើតបន្ថែមទៀតនូវគោលការណ៍នៃសវនាការយុត្តិធម៌ ដោយរួមបញ្ចូលមិនត្រឹមតែសិទ្ធិ និងគោលកាណ៍ដូចជា ៖ សិទ្ធិទទួលបានសវនាការជាសាធារណៈ[3] សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេល[4] សិទ្ធិយល់ពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់[5] សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់

[1] មាត្រា១០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨, http://bit.ly/1gisTm1 ។

[2] មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់អង្គមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦, http://bit.ly/1j1mTd1 ។

[3] មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[4] មាត្រា១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[5] មាត្រា១៤(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

ក្នុងការរៀបចំការពារក្តី[6] សិទ្ធិមានមេធាវី[7] សិទ្ធិទទួលបានការសន្មតជាមុនថាគ្មានទោស[8] សិទ្ធិមិនឆ្លើយដាក់បន្ទុកលើខ្លួនឯង (មិនសារភាពទោសកំហុសដោយសារតែការបង្ខិតបង្ខំ ឬការលួងលោម)[9] និងសិទ្ធិប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់លើផ្នែកអង្គហេតុ និងអង្គច្បាប់[10]។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើ ក.អ.ស.ព.ន នៅឆ្នាំ១៩៩២ និងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញ[11] បញ្ញត្តអំពីកាតព្វកិច្ចគោរពសិទ្ធិមនុស្សអន្តរជាតិទៅក្នុងច្បាប់ជាតិ និងគោលនយោបាយរបស់ប្រទេស។ ហេតុដូច្នេះ បទដ្ឋានគតិយុត្តស្តីពីសិទ្ធិមនុស្សអន្តរជាតិនានា រួមទាំងបទប្បញ្ញត្តិនៃ ក.អ.ស.ព.ន មានអានុភាពអនុវត្តដោយផ្ទាល់នៅក្នុងតុលាការកម្ពុជា ដូចដែលបានបញ្ជាក់បន្ថែមតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញកាលពីឆ្នាំ២០០៧។[12]

## ១.១.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌តាមច្បាប់ជាតិ

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានការពារនៅកម្ពុជា តាមរយៈបទប្បញ្ញត្តិជាក់លាក់និងទូទៅមួយចំនួន ដែលមានចែងនៅក្នុងលិខិតូបករណ៍មួយចំនួន។ រដ្ឋធម្មនុញ្ញបញ្ញត្តពីក្របខ័ណ្ឌជាមូលដ្ឋានចំពោះការជំនុំជម្រះដោយយុត្តិធម៌។ មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកំណត់អំពីសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ និងការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយធានាថា ៖

- មិនត្រូវឲ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ។
- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ នឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។
- ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឲ្យធ្វើឡើយ។ អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់។
- ការទទួលសារភាព ដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។
- វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

---

[6] មាត្រា១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[7] មាត្រា១៤(៣)(ឃ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[8] មាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[9] មាត្រា១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[10] មាត្រា១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

[11] មាត្រា៣១ នៃរដ្ឋធម្មនុញ្ញ ៖ *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាននូវពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។"*
http://bit.ly/1hcJqYV

[12] សេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ របស់ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧។

- ជនជាប់ចោទណាក៏ដោយ ត្រូវចាត់ទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។
- ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

ម្យ៉ាងវិញទៀត មាត្រា ៥១ មាត្រា ១២៨ មាត្រា ១៣០ និង មាត្រា ១៣២ នៃរដ្ឋធម្មនុញ្ញក៏បញ្ញត្តអំពីការបែងចែកអំណាច និងឯករាជ្យភាពរបស់តុលាការដែលធានាដោយព្រះមហាក្សត្រផងដែរ។

ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") ត្រូវបានអនុម័តក្នុងឆ្នាំ២០០៧[13] ចែងយ៉ាងលម្អិតអំពីនីតិវិធីដែលត្រូវអនុវត្តលើជនសង្ស័យ និងកំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ចៅក្រម ព្រះរាជអាជ្ញា និងភាគីជនជាប់ចោទ ដោយគិតចាប់ពីការផ្តួចផ្តើមនៃការស៊ើបអង្កេតបឋមពេលចាប់ខ្លួននៅក្នុងនីតិវិធីព្រហ្មទណ្ឌទាំងមូល រហូតដល់ការបញ្ចប់បណ្តឹងឧបាស្រ័យចុងក្រោយ។

ជាចុងក្រោយ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមព្រហ្មទណ្ឌ") ដែលត្រូវបានប្រកាសឲ្យប្រើក្នុងឆ្នាំ២០០៩ និងបានចូលជាធរមានទាំងស្រុងកាលពីខែធ្នូ ឆ្នាំ២០១០ ចែងអំពីចំណាត់ថ្នាក់នៃបទល្មើស គោលការណ៍នៃការទទួលខុសត្រូវព្រហ្មទណ្ឌ និងគោលការណ៍នៃការផ្តន្ទាទោស។

បន្ថែមពីលើនេះទៀត កាលពីខែមិថុនា ឆ្នាំ២០០៣ គណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") បានអនុម័តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ("យុទ្ធសាស្ត្រ")។[14] យុទ្ធសាស្រ្តនេះកំណត់អំពីគោលការណ៍ណែនាំចំនួន ៤ ដែលកើតចេញពីបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ដើម្បីឈានទៅដល់ការធ្វើកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌រួមមាន ៖ សិទ្ធិរបស់បុគ្គល លទ្ធិប្រជាធិបតេយ្យសេរី ការបែងចែកអំណាច និងនីតិរដ្ឋ។ យុទ្ធសាស្រ្តនេះក៏កំណត់អំពីកម្មវត្ថុជាយុទ្ធសាស្រ្តចំនួន ៧ ដែលបង្កើតបានជាមូលដ្ឋានគ្រឹះនៃផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០០៥។[15]

## ១.២. គោលបំណង វិសាលភាព និង វិធីសាស្រ្ត

គោលបំណងនៃគម្រោង គឺធ្វើការប្រមូលទិន្នន័យ ដែលអាចយកមកវិភាគ ដើម្បីកំណត់អំពីចំណុចខ្លាំង និងចំណុចខ្សោយនានានៅក្នុងប្រព័ន្ធយុត្តិធម៌។ តាមរយៈការទាញយកចំណាប់អារម្មណ៍ទៅលើបញ្ហានេះនៅក្នុងដំណើរការសវនាការ ដែលតម្រូវឲ្យមានការលើកកម្ពស់ឲ្យប្រសើរឡើងនៅក្នុងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងធ្វើការផ្តល់អនុសាសន៍ជាក់លាក់ទៅកាន់ស្ថាប័នយុត្តិធម៌ពាក់ព័ន្ធ

[13] ក្រមនីតិវិធីព្រហ្មទណ្ឌជំនួសឲ្យផ្នែកនៃបទប្បញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល ឆ្នាំ១៩៩២ ("ច្បាប់អ៊ុនតាក់")។

[14] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌, យុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៣។

[15] ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ផែនការសកម្មភាពសម្រាប់ការអនុវត្តន៍យុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលត្រូវបានរៀបចំឡើង ដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងកិច្ចប្រជុំពេញអង្គនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។

មួយចំនួន ម.ស.ម.ក គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងទាំងឡាយក្នុងការពង្រឹង និងកំណែទម្រង់ប្រព័ន្ធយុត្តិធម៌ សម្រាប់ជាប្រយោជន៍ចំពោះប្រជាពលរដ្ឋគ្រប់រូប។

ចាប់ពីខែសីហា ឆ្នាំ២០០៩ ដល់ខែមករា ឆ្នាំ២០១៣ គម្រោងបានសង្កេតសវនាការនៅសាលាដំបូងរាជធានីភ្នំពេញ សាលាដំបូងខេត្តកណ្ដាល សាលាដំបូងខេត្តបន្ទាយមានជ័យ និងសាលាដំបូងខេត្តរតនគិរី ហើយបានចេញផ្សាយរបាយការណ៍ប្រចាំឆមាសស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះ ដោយយុត្តិធម៌ចំនួន ៦ លើក។[16] នៅខែមករា ឆ្នាំ២០១៣ គម្រោងបានបញ្ចប់សកម្មភាពសង្កេតការណ៍របស់ខ្លួននៅតាមសាលាដំបូង ដើម្បីផ្ដោតលើការសង្កេតការណ៍នៅសាលាឧទ្ធរណ៍វិញម្ដង។ គម្រោងបានសម្រេចធ្វើការសង្កេតការណ៍នៅសាលាឧទ្ធរណ៍ ដើម្បីវាយតម្លៃអំពីបទដ្ឋានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានអនុវត្តនៅតុលាការជាន់ខ្ពស់។ គោលដៅគឺដើម្បីផ្ដល់ការវិភាគអំពីនិន្នាការទាក់ទងនឹងការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលកើតឡើងនៅសាលាឧទ្ធរណ៍ និងដើម្បីបង្កើតបានជាក្របខ័ណ្ឌមួយ ដែលអាចដាក់ចេញនូវអនុសាសន៍ ហើយធ្វើឲ្យប្រសើរឡើងក្នុងការអនុវត្តន៍។

គម្រោងផ្ដោតទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាក់លាក់មួយចំនួន។ ដើម្បីកំណត់ថាតើសិទ្ធិណាខ្លះដែលត្រូវពិចារណា ម.ស.ម.ក ពឹងផ្អែកលើប្រភពពីខាងក្រៅដូចជារបាយការណ៍ និងការសិក្សាស្រាវជ្រាវផ្សេងៗអំពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា និងអំពីប្រព័ន្ធយុត្តិធម៌កម្ពុជា។ លើសពីនេះទៀត ការសង្កេតការណ៍នៅសាលាឧទ្ធរណ៍ នាំឲ្យ ម.ស.ម.ក ផ្ដោតលើធាតុផ្សំជាក់លាក់មួយចំនួនផ្សេងទៀតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានលក្ខណៈខុសប្លែកគ្នាពីអ្វីដែល ម.ស.ម.ក បានអនុវត្តសកម្មភាពសង្កេតការណ៍របស់ខ្លួននៅឯសាលាដំបូង។

សិទ្ធិខាងក្រោមត្រូវបានជ្រើសរើសសម្រាប់គោលបំណងនៃការសង្កេតការណ៍ ៖

- សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ
- សិទ្ធិយល់ដឹងអំពីបទចោទប្រកាន់
- សិទ្ធិទទួលបានការពន្យល់ប្រាប់សិទ្ធិដល់ជនជាប់ចោទ ឬពិរុទ្ធជន
- សិទ្ធិមានមេធាវី និងមានវត្តមាននៅក្នុងសវនាការ
- សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស
- សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលម្អៀង
- សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាព
- សិទ្ធិបង្ហាញភស្ដុតាង (រួមទាំងសិទ្ធិហៅ និងសាកសួរសាកស្សី)
- សិទ្ធិទទួលបាននូវសេចក្ដីសម្រេចប្រកបដោយសម្អាងហេតុច្បាស់លាស់
- សិទ្ធិទទួលដឹងពួភស្ដុតាងសម្រាប់រៀបចំការពារខ្លួន

---

[16] របាយការណ៍ប្រចាំឆមាសលើកទី៦ ស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ដែលអាចស្វែងរកបានតាមរយៈ ៖ http://bit.ly/M7mkET ។

- ការហាមឃាត់ប្រឆាំងទៅនឹងការអនុវត្តន៍អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ (ត្រូវបានជំនុំជម្រះចំពោះបទល្មើស ដែលអំពើនោះមិនមែនជាបទល្មើសក្នុងពេលដែលសកម្មភាពនោះត្រូវបានប្រព្រឹត្ត)
- ការហាមឃាត់ចំពោះការផ្តន្ទាទោសពីរដងចំពោះបទល្មើសដដែល និង
- សិទ្ធិជនជាប់ចោទ ឬពិរុទ្ធជនជាអនីតិជន។

អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ចូលរួមសង្កេតការណ៍សវនាការព្រហ្មទណ្ឌនៅសាលាឧទ្ធរណ៍ជារៀងរាល់ថ្ងៃធ្វើការ។ ដើម្បីឲ្យការកត់ត្រាទិន្នន័យពាក់ព័ន្ធនឹងការជំនុំជម្រះឲ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល ម.ស.ម.ក បានបង្កើតតារាងសង្កេតការណ៍សវនាការ ("តារាងសង្កេតការណ៍")[17] សម្រាប់ប្រើប្រាស់នៅសាលាឧទ្ធរណ៍។ តារាងសង្កេតការណ៍នេះត្រូវបានបង្កើតស្របតាមបរិបទរបស់គម្រោង និងមានជាង ៧០ សំណួរ ដែលឆ្លើយតបទៅនឹងថាតើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ណាខ្លះ ដែលត្រូវបានគោរពតាមដោយតុលាការ។ ជាកិច្ចប្រឹងប្រែងដើម្បីធានានូវនិរន្តរភាពនៃកិច្ចសហការក្នុងន័យស្ថាបនា ម.ស.ម.ក បានបង្ហាញ និងពន្យល់អំពីតារាងសង្កេតការណ៍ និងសកម្មភាពសង្កេតការណ៍របស់ខ្លួនដល់តំណាងរបស់សាលាឧទ្ធរណ៍។ ម.ស.ម.ក ក៏បានបង្កើតឧបសម្ព័ន្ធចំនួន ១ ទំព័រភ្ជាប់ជាមួយនឹងតារាងសង្កេតការណ៍ សម្រាប់ប្រើប្រាស់ក្នុងសវនាការដែលជាប់ពាក់ព័ន្ធនឹងជនជាប់ជាប់ចោទជាអនីតិជនផងដែរ។ ដោយការថ្លឹងថ្លែងលើភាពខ្លី និងច្បាស់លាស់របស់តារាងសង្កេតការណ៍ ម.ស.ម.ក បានចងក្រងសេចក្តីណែនាំអំពីការប្រើប្រាស់តារាងសង្កេតការណ៍យ៉ាងល្អិតល្អន់ ("សេចក្តីណែនាំ")[18] ដើម្បីធានាអំពីការបកស្រាយសំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍ និងការយល់ដឹងលើមូលដ្ឋានច្បាប់ ព្រមទាំងគោលបំណងនៃសំណួរនីមួយៗឲ្យមានភាពស៊ីសង្វាក់គ្នាតែមួយ។ អ្នកសង្កេតការណ៍ ក៏ត្រូវបានផ្តល់ជូននូវបញ្ជីច្បាប់ ដែលគូសបញ្ជាក់អំពីច្បាប់ជាតិ និងអន្តរជាតិពាក់ព័ន្ធ ដើម្បីគាំទ្រដល់សំណួរនីមួយៗនៅក្នុងតារាងសង្កេតការណ៍។

ជាចុងក្រោយ ម.ស.ម.ក ប្តេជ្ញាគោរពតាមគោលការណ៍អន្តរជាតិ ដែលអនុវត្តចំពោះការសង្កេតការណ៍សវនាការ[19] និងបានបង្កើតនូវក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍របស់ខ្លួន ("ក្រមសីលធម៌")។[20] ក្រមសីលធម៌សម្រាប់អ្នកសង្កេតការណ៍ គូសបញ្ជាក់ពីកាតព្វកិច្ចមិនជ្រៀតជ្រែក ភាពមិនលម្អៀង និងការរក្សាការសម្ងាត់ ដែលមន្ត្រីសង្កេតការណ៍ត្រូវគោរពតាម។

---

[17] តារាងសង្កេតការណ៍សវនាការឧទ្ធរណ៍, http://bit.ly/1fbDUEx ។

[18] សេចក្តីណែនាំសម្រាប់ការប្រើប្រាស់តារាងសង្កេតការណ៍សវនាការឧទ្ធរណ៍របស់ ម.ស.ម.ក, http://bit.ly/1fbDZYO ។

[19] សូមមើល ៖ អង្គការលើកលែងទោសអន្តរជាតិ *សៀវភៅស្តីពីការជំនុំជម្រះ ដោយយុត្តិធម៌របស់អង្គការលើកលែងទោសអន្តរជាតិ* (ទីក្រុងឡុងដ៍៖ការបោះពុម្ពផ្សាយរបស់អង្គការលើកលែងទោសអន្តរជាតិឆ្នាំ១៩៩៨) AI Index POL 30/02/98, ភីជីកដេលេណា និងវ៉ាណោសាលេសនី, *តើអ្វីទៅជាការជំនុំជម្រះដោយយុត្តិធម៌?៖ សេចក្តីណែនាំជាមូលដ្ឋានស្តីពីបទដ្ឋានច្បាប់និងការអនុវត្តន៍* (ទីក្រុងញូវយ៉ក៖ គណៈកម្មាធិការមេធាវីសម្រាប់សិទ្ធិមនុស្សឆ្នាំ២០០០), អង្គការសន្តិសុខនិងសហប្រតិបត្តិការអឺរ៉ុប/ការិយាល័យវិទ្យាស្ថានប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស, *ការសង្កេតការណ៍សវនាការ ៖ សៀវភៅយោងសម្រាប់អ្នកអនុវត្ត* (ប្រទេសប៉ូឡូញ៖ OSCE/ODIHR ឆ្នាំ២០០៨), និង អូលីវើរ៉ាបាបារ៉ា និងលីនដាបេសារ៉ាទីម៉ូរ៉ាអែដ, *សៀវភៅស្តីពីការសង្កេតការណ៍សវនាការរបស់គណៈកម្មការអ្នកច្បាប់អន្តរជាតិ* (ទីក្រុងហ្សឺណែវ ៖ គណៈកម្មការអ្នកច្បាប់អន្តរជាតិ ឆ្នាំ២០០២)។

[20] ក្រមសីលធម៌សង្កេតការណ៍សវនាការរបស់ ម.ស.ម.ក, http://bit.ly/1fbE3Yu ។

នៅក្នុងការអនុវត្តន៍សកម្មភាពសង្កេតការណ៍របស់ខ្លួន ការជំនុំជម្រះជាក់លាក់ គឺពុំត្រូវបានផ្តោតជាគោលដៅសំខាន់នោះទេ ផ្ទុយទៅវិញសវនាការត្រូវបានសង្កេតការណ៍តាមចិត្តដោយសេរី ដែលអាស្រ័យលើកាលវិភាគរបស់តុលាការ ដើម្បីធានាថាដំណើរការនៃការប្រមូលទិន្នន័យនៅតែរក្សាគោលបំណងរបស់គម្រោងបាន។ នៅពេលដែលអ្នកសង្កេតការណ៍ចុះទៅធ្វើការសង្កេតសវនាការណាមួយ ព័ត៌មានត្រូវបានកត់ត្រាទុកដោយផ្ទាល់ទៅក្នុងតារាងសង្កេតការណ៍។ ព័ត៌មានដែលស្វែងរក គឺមានកម្រិតទៅតាមដំណើរការសវនាការផ្ទាល់ និងពុំមានកិច្ចសម្ភាសន៍ ឬ កិច្ចពិភាក្សាបន្ថែមទៀតត្រូវបានធ្វើឡើងនោះទេ លើកលែងតែនៅពេល ដែលអ្នកសង្កេតការណ៍សវនាការខិតខំស្វែងរកព័ត៌មានទាក់ទិនទៅនឹងសាលដីកានៃការជំនុំជម្រះដែលពុំត្រូវបានប្រកាសនៅថ្ងៃសវនាការ តែត្រូវបានលើកទៅប្រកាសនៅកាលបរិច្ឆេទក្រោយៗទៀត។

បន្ទាប់ពីសវនាការនីមួយៗ ទិន្នន័យនៅក្នុងតារាងសង្កេតការណ៍ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ("ប្រព័ន្ធគ្រប់គ្រងទិន្នន័យ")។[21]

ម.ស.ម.ក វិភាគទិន្នន័យសវនាការដែលកត់ត្រាទុកក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ហើយធ្វើកំណត់សម្គាល់ការអនុវត្តន៍វិជ្ជមាននានា ក៏ដូចជាបញ្ហាគួរឲ្យព្រួយបារម្ភ ដែលកើតចេញពីសវនាការជំនុំជម្រះ។ គោលបំណងសំខាន់បំផុតនៃការវិភាគ គឺដើម្បីកំណត់ចំណុចខ្លាំង និងចំណុចខ្សោយទាំងឡាយនៅសាលាឧទ្ធរណ៍ និងដើម្បីពិភាក្សាបញ្ហាទាំងអស់នេះជាមួយនឹងតុលាការ ព្រមទាំងដៃគូពាក់ព័ន្ធនឹងវិស័យច្បាប់ផ្សេងទៀត ក្នុងន័យបង្កើត និងអនុវត្តវិធីសាស្ត្រមួយចំនួនដើម្បីធ្វើឲ្យប្រសើរឡើងដល់ការការពារសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅតុលាការកម្ពុជា។ ក្នុងរយៈពេលប៉ុន្មានឆ្នាំបន្ទាប់ទៀត នៅខណៈដែលសកម្មភាពសង្កេតការណ៍សវនាការនឹងនៅតែបន្ត ប្រព័ន្ធគ្រប់គ្រងទិន្នន័យនឹងត្រូវប្រើសម្រាប់វិភាគបែបប្រៀបធៀប និងកំណត់អំពីនិន្នាការក្នុងការអនុវត្តន៍របស់សាលាឧទ្ធរណ៍ វាយតម្លៃអំពីភាពប្រសើរឡើង និងចង្អុលបង្ហាញពីអនុសាសន៍បន្ថែមទៀត។

សេចក្តីព្រាងរបាយការណ៍ចុងក្រោយ ត្រូវបានផ្ញើជូនប្រធានសាលាឧទ្ធរណ៍ ដើម្បីផ្តល់មតិយោបល់ និងអនុសាសន៍ មុនពេលបោះពុម្ពរបាយការណ៍នេះ។ នៅពេលដែលរបាយការណ៍ត្រូវបានបោះពុម្ពភ្លាម បុគ្គលិកគម្រោងស្នើសុំឲ្យមានកិច្ចប្រជុំជាក់លាក់មួយចំនួនជាមួយនឹងតំណាងរបស់សាលាឧទ្ធរណ៍ ក៏ដូចជាអង្គការ អង្គភាព និងស្ថាប័នធ្វើការលើវិស័យយុត្តិធម៌ផ្សេងៗទៀត ដែលស្ថាប័នទាំងនោះអាចដោះស្រាយអនុសាសន៍ដែលបានលើកឡើង។ កិច្ចប្រជុំបែបនេះ ជាមូលដ្ឋានគ្រឹះសម្រាប់ការផ្លាស់ប្តូរគំនិត និងផ្តល់ការយល់ដឹងលម្អិតអំពីបញ្ហាប្រឈមរបស់ស្ថាប័នដែលធ្វើការ ដើម្បីពង្រឹងប្រព័ន្ធយុត្តិធម៌។ ការជួបពិគ្រោះយោបល់គ្នាមានគោលបំណងក្នុងការលើកកម្ពស់ការអនុវត្តន៍អនុសាសន៍ ដែលរបាយការណ៍បានដាក់ចេញ។

[21] ប្រព័ន្ធគ្រប់គ្រងទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក, http://bit.ly/1fbEbHE ។

## ២. ទិន្នន័យ និង ការវាយតម្លៃលើការអនុវត្តន៍សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

ផ្នែកនេះនៃរបាយការណ៍ កំណត់អំពីទិន្នន័យ "ដើម" ដែលកត់ត្រាក្នុងតារាងសង្កេតការណ៍សវនាការ ចំនួន ២០៤ ដែលបានសង្កេតនៅសាលាឧទ្ធរណ៍ ចាប់ពីថ្ងៃទី១ ខែមីនា ឆ្នាំ២០១៣ ដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ ២០១៤ ព្រមទាំងវាយតម្លៃទិន្នន័យទាំងនេះ។

សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍[22] រួមបញ្ចូលទាំងសិទ្ធិឲ្យពិនិត្យមើលសំណុំរឿងយ៉ាងពេញលេញ។ និយាយតាមមួយបែបទៀត ការពិនិត្យមើលលើបណ្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងទាំងលើទិដ្ឋភាពច្បាប់ និងសម្ភារៈរបស់បុគ្គលដែលត្រូវបានចោទប្រកាន់ និងផ្តន្ទាទោស។[23] ហេតុដូច្នេះ ការពិនិត្យមើលនេះត្រូវតែ "វាយតម្លៃភស្តុតាងឲ្យបានគ្រប់ជ្រុងជ្រោយ និងបើកសវនាការជំនុំជម្រះ"។[24]

### តួលេខទី១(ក) ៖ សវនាការឧទ្ធរណ៍ដែលបានសង្កេត - បទឧក្រិដ្ឋ និងបទមជ្ឈិម

| ទិន្នន័យ | បទឧក្រិដ្ឋ | | បទមជ្ឈិម | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| | ១១៤ | ៥៦ | ៩០ | ៤៤ |
| ចំនួនសវនាការសរុប | ២០៤ | | | |

តួលេខទី១(ក)ខាងលើនេះ បង្ហាញអំពីចំនួនសវនាការព្រហ្មទណ្ឌ ដែលបានសង្កេតដោយអ្នកសង្កេតការណ៍សវនាការនៅក្នុងអំឡុងពេលរបាយការណ៍ និងបែងចែកបទចោទជាពីរចំណាត់ថ្នាក់នៃបទល្មើសផ្សេងគ្នា។ មាត្រា ៤៦ នៃក្រមព្រហ្មទណ្ឌកំណត់និយមន័យនៃបទឧក្រិដ្ឋថា ជាបទល្មើសទាំងឡាយណា ដែលអតិបរមានៃទោសដាក់ពន្ធនាគារអស់មួយជីវិត និងទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៥ ឆ្នាំ និងក្រោម ឬ ស្មើនឹង ៣០ ឆ្នាំ។ មាត្រា ៤៧ បានឲ្យនិយមន័យបទមជ្ឈិមថា ជាបទល្មើសទាំងឡាយណា ដែលអតិបរមានៃទោសដាក់ពន្ធនាគារមានរយៈពេលលើសពី ៦ ថ្ងៃ និងក្រោម ឬ ស្មើនឹង ៥ ឆ្នាំ។[25]

---

[22] មាត្រា១៤(៥) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

[23] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីសម្រេចលេខ ៧០១/១៩៩៦, ហ្គូមេស ទល់នឹង ប្រទេសអេស្ប៉ាញ (ទស្សនៈនេះត្រូវបានអនុម័តនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៨) នៅក្នុងឯកសាររបស់ អ.ស.ប លេខ GAOR, ក/៥៥/៤០ (លេខ២) ទំព័រទី១០៩ កថាខណ្ឌទី១១.១, http://bit.ly/1bhUzWm ។

[24] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីសម្រេចលេខ ៦២៣, ៦២៤, ៦២៦, ៦២៧/១៩៩៥, វី ភី ឌូម៉ុកូវស្គី ទល់នឹង ប្រទេសហ្សកហ្ស៊ី (ទស្សនៈនេះត្រូវបានអនុម័តនៅថ្ងៃទី៦ ខែមេសា ឆ្នាំ១៩៩៨) នៅក្នុងឯកសាររបស់ អ.ស.ប លេខ GAOR, ក/៥៥/៤០ (លេខ២) ទំព័រទី១១១ កថាខណ្ឌទី១៨.១១។

[25] មាត្រា៤៨ នៃក្រមព្រហ្មទណ្ឌ។

### តួលេខទី១(ខ) ៖ សវនាការឧទ្ធរណ៍ដែលបានសង្កេត - ភាគីធ្វើបណ្តឹងឧទ្ធរណ៍

| ទិន្នន័យ | ប្តឹងដោយពិរុទ្ធជន | | ប្តឹងដោយតំណាងអយ្យការ* | | ប្តឹងដោយតំណាងអយ្យការ និងជនជាប់ចោទ | | ប្តឹងដោយដើមបណ្តឹងរដ្ឋប្បវេណី | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| | ១៨២ | ៨៩ | ២០ | ១០ | ១ | ០,៥ | ១ | ០,៥ |
| ចំនួនសវនាការសរុប | ២០៤ | | | | | | | |

*សំដៅលើតំណាងអយ្យការអមសាលាដំបូង និងមហាអយ្យការអមសាលាឧទ្ធរណ៍។

តួលេខទី១(ខ) បង្ហាញអំពីអ្នកដែលបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមរបស់សាលាដំបូង។ សាលក្រមចេញដោយសាលាដំបូងអាចត្រូវបានប្តឹងដោយព្រះរាជអាជ្ញាអមសាលាដំបូង និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ពិរុទ្ធជន ដើមបណ្តឹងរដ្ឋប្បវេណី ឬ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី (អ្នកទាំងពីរនេះអាចប្តឹងបានចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី)។[26] តួលេខនេះបង្ហាញថា បណ្តឹងឧទ្ធរណ៍ភាគច្រើន (៨៩%) ធ្វើឡើងដោយពិរុទ្ធជន។

ផ្នែកបន្ទាប់ខាងក្រោមនេះ វិភាគអំពីការអនុវត្តន៍ធាតុផ្សំនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ពាក់ព័ន្ធផ្សេងៗ ដោយសាលាឧទ្ធរណ៍នៅក្នុងអំឡុងពេលនៃរបាយកាណ៍។ សម្រាប់គោលបំណងនៃការវិភាគជាដំបូង របាយការណ៍នេះឆ្លុះបញ្ចាំងការអនុវត្តន៍ ដែលបង្ហាញពីចំណុចខ្វះខាតដែលអាចនាំឲ្យប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មុននឹងឈានដល់ការគូសបញ្ជាក់អំពីការអនុវត្តន៍វិជ្ជមានមួយចំនួន។

## ២.១. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលស្ថិតក្នុងសភាពគ្រោះថ្នាក់

តាមរយៈការវិភាគដោយផ្អែកលើទិន្នន័យ ដែលប្រមូលបានក្នុងអំឡុងពេលរបាយការណ៍ មានការបង្ហាញថានៅមានចំណុចខ្វះខាតក្នុងការធានាអនុវត្តសិទ្ធិមួយចំនួន និង/ឬ ការអនុវត្តន៍នៅពុំទាន់បានពេញលេញនៅឡើយទេ ហេតុដូច្នេះ សិទ្ធិរបស់បុគ្គលក្នុងការទទួលបានសវនាការដោយយុត្តិធម៌អាចនឹងមិនត្រូវបានធានាឲ្យបានពេញលេញ។

### ២.១.១. សិទ្ធិទទួលបានសវនាការជាសាធារណៈ

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ៖**

- **មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ** ៖*"ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជម្រះក្តី។ ជនគ្រប់រូបត្រូវមានសិទ្ធិឲ្យសាលាក្តីមានសមត្ថ*

[26] មាត្រា៣៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

> *កិច្ចឯករាជ្យ និងមិនលម្អៀងដែលបង្កើតដោយច្បាប់ជំនុំជម្រះរឿងក្តីរបស់ខ្លួនដោយសមធម៌ និងជាសាធារណៈដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ[...]។"*
>
> - **មាត្រា ៣៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖*"ការពិភាក្សាដេញដោលប្រព្រឹត្តទៅនៅពេលសវនាការ ជាសាធារណៈ។"*

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការសម្រេចថាមានពិរុទ្ធភាព ឬ គ្មានទោសនៅក្នុងសវនាការជាសាធារណៈ លើកលែងតែក្នុងករណីពិសេសជាក់លាក់មួយចំនួន ឧទាហរណ៍ ៖ នៅពេលដែលតុលាការយល់ឃើញថា សវនាការជាសាធារណៈនឹងបង្កឲ្យមាន *"ការប៉ះពាល់ធ្ងន់ធ្ងរ"* ដល់សណ្តាប់ធ្នាប់សង្គម ឬដល់ទំនៀមទម្លាប់ដ៏ល្អប្រពៃ។[27] សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈពាក់ព័ន្ធនឹងធាតុផ្សំមួយចំនួន ៖ សវនាការគួរតែបើកចំហជាទូទៅសម្រាប់សាធារណជន និងត្រូវបានធ្វើឡើងដោយផ្ទាល់មាត់ ព័ត៌មានពីទីកន្លែង និងកាលបរិច្ឆេទនៃសវនាការគួរតែអាចរកបានជាសាធារណៈ ហើយគួរតែមានសម្ភារៈរូបវន្តគ្រប់គ្រាន់ដើម្បីធានាការចូលរួមពីសាធារណជន។[28]

## តួលេខទី២ ៖ សិទ្ធិទទួលបានសវនាការជាសាធារណៈ

| ទិន្នន័យ | មាន | | គ្មាន | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| តើការជូនដំណឹងអំពីសវនាការត្រូវបានបិទផ្សាយលើក្តារខៀនក្រៅបន្ទប់សវនាការដែរឬទេ? | ១៣៣ | ៦៥ | ៧១ | ៣៥ |
| តើសាធារណជនត្រូវបានរារាំង ឬបណ្តេញចេញពីបន្ទប់សវនាការដែរឬទេ? | ០ | ០ | ២០៤ | ១០០ |

នៅពេលដែល ម.ស.ម.ក បានចាប់ផ្តើមសកម្មភាពសង្កេតការណ៍របស់ខ្លួននៅសាលាឧទ្ធរណ៍ ពុំមានការជូនដំណឹងអំពីសវនាការត្រូវបានបិទផ្សាយនោះទេ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីមានការលើកឡើងអំពីបញ្ហានេះនៅក្នុងជំនួបជាមួយនឹងតំណាងរបស់សាលាឧទ្ធរណ៍កាលពីខែមេសា ឆ្នាំ២០១៣ គម្រោងបានសង្កេតឃើញថា ការជូនដំណឹងអំពីសវនាការត្រូវបានបិទផ្សាយលើក្តារខៀននៅខាងក្រៅបន្ទប់សវនាការ។ ប៉ុន្តែ ការបិទផ្សាយនេះនៅតែពុំទាន់អនុវត្តឲ្យបានស៊ីសង្វាក់គ្នា ដោយសារតែទិន្នន័យបង្ហាញថា មាន

---

[27] មាត្រា៣១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា បើតុលាការយល់ឃើញថាសាធារណភាពបង្កឲ្យមានគ្រោះថ្នាក់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬដល់ទំនៀមទម្លាប់ នោះតុលាការតាមសេចក្តីសម្រេចមានសម្អាងហេតុ អាចបង្គាប់ឲ្យការពិភាក្សាដេញដោលទាំងស្រុង ឬមួយផ្នែកប្រព្រឹត្តទៅជាសម្ងាត់។ មាត្រា១៤(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ បញ្ញត្តថា សារព័ត៌មាន និងសាធារណជនអាចមិនឲ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការសម្រាប់ផលប្រយោជន៍នៃ *"ទំនៀមទម្លាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ"* ដែលថាការធ្វើជាសាធារណៈនឹងនាំឲ្យខូចខាតដល់ផលប្រយោជន៍យុត្តិធម៌ ឬនៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ។

[28] គណៈកម្មាធិការសិទ្ធិមនុស្សសេចក្តីសម្រេចរបស់គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីជូនដំណឹងលេខ២១៥/១៩៨៦, *ជី.អា.វ៉ាន់មើស តទល់នឹង ប្រទេសហូឡង់*, សេចក្តីសម្រេចចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩០(CCPR/គ/៣៩/ឃ/២១៥/១៩៨៦) កថាខណ្ឌទី៦.២។ យោងនៅក្នុងកំណត់ហេតុពិសេសលេខ១២, http://bit.ly/1joZ8AG ។

ត្រឹមតែចំនួន ៦៥% នៃសវនាការ ដែលមានការបិទផ្សាយសេចក្តីជូនដំណឹងនៅក្រៅបន្ទប់សវនាការ។ បន្ថែមពីលើនេះទៀត ព័ត៌មានសំខាន់ៗដូចជា លេខសំណុំរឿង ឈ្មោះរបស់ភាគី បទចោទប្រកាន់ ជាដើម នៅក្នុងសំណុំរឿងជាច្រើនពុំត្រូវបានបិទនោះទេ។

នៅក្នុងអំឡុងពេលនៃការពិភាក្សាជាមួយនឹងប្រធានសាលាឧទ្ធរណ៍[29] លោកប្រធានបានទទួលស្គាល់ថា ការបិទផ្សាយកម្មវិធីជំនុំជម្រះដោយមានព័ត៌មានល្អិតល្អន់គ្រប់គ្រាន់ជាចំណុចខ្វះខាត ក៏ប៉ុន្តែលោកប្រធានបានលើកឡើងថា ជារឿយៗកន្លងមកមានការប្រជុំ និងបានណែនាំដល់ក្រឡាបញ្ជីនាយករួចហើយក្នុងការចាត់ចែងបញ្ហានេះឲ្យបានប្រសើរជាងមុន ដើម្បីផ្តល់ភាពងាយស្រួលដល់សាធារណជន។

## ២.១.២. សិទ្ធិយល់ដឹងពីបទចោទប្រកាន់

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ៖**

- **មាត្រា១៤(៣)(ក) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ៖** *ជនជាប់ចោទ "ត្រូវទទួលបានព័ត៌មានភ្លាមៗ និងដោយលម្អិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួនជាភាសាដែលជននោះចេះ។"*
- **មាត្រា១៤(៣)(ច) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ៖** *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមាដោយស្មើភាពគ្នាយ៉ាងពេញលេញ... ទទួលបានអ្នកបកប្រែភាសា ដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងតុលាការ។"*
- **មាត្រា៣២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖ *"ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់មើលអត្តសញ្ញាណជនទាំងនោះ។"*
- **មាត្រា៣២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖ *"ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រាប់ជនជាប់ចោទឲ្យដឹងអំពីបទចោទដែលគេចោទប្រកាន់មកលើខ្លួន។"*
- **មាត្រា៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖ *"ក្នុងករណីចាំបាច់ប្រធានអាចហៅរកអ្នកបកប្រែ។"*
- **មាត្រា៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖ *"កាលណាសំណួរត្រូវសួរដល់ជនគ និងថ្លង់ ក្រឡាបញ្ជីត្រូវសរសេរសំណួរ ហើយឲ្យសាមីខ្លួនអាន និងឆ្លើយជាលាយល័ក្ខណ៍អក្សរ។ ក្នុងករណីសាមីជនមិនចេះអាន ឬ មិនចេះអក្សរ ប្រធានត្រូវរកអ្នកបកប្រែក្នុងលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៣៣០ [...] ប្រធានសវនាការអាចហៅរកអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជនគ និងថ្លង់នោះ មកបកប្រែ។*
- **មាត្រា៣៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖ *"លើសពីនេះ វិធានដែលអនុវត្តចំពោះតុលាការជាន់ដំបូងត្រូវយកមកអនុវត្តចំពោះសាលាឧទ្ធរណ៍។"*

[29] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងលោក ប៊ុន សាវ៉ាត់ នាយកក្រឡាបញ្ជី នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៤។

ជនទាំងឡាយណាដែលជាប់ចោទពីបទល្មើសព្រហ្មទណ្ឌ ត្រូវតែទទួលបាននូវការជូនដំណឹងអំពីបទចោទប្រកាន់ ដែលជននោះត្រូវបានចោទប្រកាន់។ ប្រសិនជាពុំមានព័ត៌មានសំខាន់បែបនេះទេ វាពិតជាមិនអាចទៅរួចនោះទេក្នុងការរៀបចំការពារក្តីឲ្យបានត្រឹមត្រូវ ឬផ្តល់ការណែនាំឲ្យបានល្អិតល្អន់ដល់មេធាវីនៅក្នុងសំណុំរឿង ដែលជនជាប់ចោទមានមេធាវីការពារតាមផ្លូវច្បាប់។ អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ប្រមូលទិន្នន័យទាក់ទងនឹងព័ត៌មាន ដែលត្រូវបានប្រាប់ដល់ពិរុទ្ធជននៅពេលចាប់ផ្តើមសវនាការ។ ទោះបីជាព័ត៌មាននេះ គួរតែត្រូវបានប្រាប់ដល់ជនជាប់ចោទរួចហើយ នៅក្នុងអំឡុងពេលនៃនីតិវិធីមុនសវនាការ/ការស៊ើបសួរ ក៏នៅតែមានសារសំខាន់សម្រាប់ចៅក្រមក្នុងការរម្លឹកដល់ពិរុទ្ធជនអំពីព័ត៌មាននេះ មុនពេលចាប់ផ្តើមសវនាការ។ នេះគឺជាករណីពិសេសដោយឡែក ដោយសារតែពេលខ្លះ បទចោទអាចត្រូវបានផ្លាស់ប្តូរ ឬកែប្រែនៅចន្លោះពេលនៃការចាប់ខ្លួនដំបូង/ការចោទប្រកាន់ និងពេលសវនាការ។

### តួលេខទី៣ ៖ សិទ្ធិយល់ដឹងពីបទចោទប្រកាន់

| ទិន្នន័យ | មាន | | គ្មាន | | មិនពាក់ព័ន្ធ | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| តើចៅក្រមបានអានរបាយការណ៍សង្ខេបនៃសំណុំរឿងទេ? | ២០៤ | ១០០ | ០ | ០ | ០ | ០ |
| តើចៅក្រមបានប្រាប់ពីបទចោទប្រកាន់ពាក់ព័ន្ធទាំងអស់ដែរឬទេនៅក្នុងរបាយការណ៍? | ១៨៦ | ៩១,២ | ០ | ០ | ១៨ | ៨,៨ |
| តើចៅក្រមប្រាប់ពីមាត្រាច្បាប់ដែលពាក់ព័ន្ធដែរឬទេនៅក្នុងរបាយការណ៍? | ១៥៥ | ៧៦ | ៤៩ | ២៤ | ០ | ០ |
| តើចៅក្រមបានប្រាប់ពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសដែរឬទេនៅក្នុងរបាយការណ៍? | ១៩៨ | ៩៧ | ៦ | ៣ | ០ | ០ |
| តើចៅក្រមបានប្រាប់ពីទីកន្លែងប្រព្រឹត្តបទល្មើសដែរឬទេនៅក្នុងរបាយការណ៍? | ១៧៩ | ៨៨ | ២៥ | ១២ | ០ | ០ |
| តើចៅក្រមបានរៀបរាប់ពីឈ្មោះភាគីដែលពាក់ព័ន្ធដែរឬទេនៅក្នុងរបាយការណ៍? | ២៤០ | ១០០ | ០ | ០ | ០ | ០ |

តួលេខខាងលើនេះបង្ហាញថា ក្នុងសំណុំរឿងជាច្រើន ចៅក្រមនៅសាលាឧទ្ធរណ៍ថ្លែងឡើងវិញអំពីបទចោទ អង្គហេតុ កាលបរិច្ឆេទ និងព័ត៌មានទាក់ទងនឹងបទចោទ។ សិទ្ធិយល់ដឹងពីបទចោទនៅក្នុងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ស្ទើរតែត្រូវបានគោរពយ៉ាងពេញលេញ។

ទោះបីជាយ៉ាងនេះក្តី បន្ថែមលើការយល់ដឹងពីបទចោទ បុគ្គលគ្រប់រូបអាចអនុវត្តសិទ្ធិតាមផ្លូវច្បាប់របស់ខ្លួនបាន លុះត្រាណាតែជននោះត្រូវបានប្រាប់យ៉ាងពេញលេញអំពីសិទ្ធិនានារបស់ខ្លួន។ ហេតុដូច្នេះ ចៅក្រមមិនគួរត្រឹមតែប្រាប់សិទ្ធិតាមផ្លូវច្បាប់ដល់ពិរុទ្ធជនប៉ុណ្ណោះនោះទេ តែក៏ត្រូវធ្វើការពន្យល់សិទ្ធិទាំងនោះផង។ ម.ស.ម.ក សង្កេតមិនត្រឹមតែថាតើចៅក្រមប្រាប់អំពីសិទ្ធិរបស់ពិរុទ្ធជនដែលត្រូវទទួលបានដូច

ដែលកំណត់នៅក្នុងតារាងខាងក្រោមនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសង្កេតទៀតថាតើចៅក្រមមានបានពន្យល់ឲ្យបានពេញលេញអំពីសិទ្ធិទាំងនោះដែរឬយ៉ាងណា។ ម.ស.ម.ក ក៏បានធ្វើកិច្ចសហប្រតិបត្តិការលើខិត្តប័ណ្ណស្តីពីសិទ្ធិទទួលបានសវនាការដោយយុត្តិធម៌ជាក់លាក់មួយចំនួនជាមួយប្រធានសាលាឧទ្ធរណ៍។ ចាប់ពីខែតុលា ឆ្នាំ២០១៣មក ខិត្តប័ណ្ណនេះត្រូវបានបិទផ្សាយនៅសាលាឧទ្ធរណ៍ និងកំណត់អំពីសិទ្ធិតាមផ្លូវច្បាប់ជាមូលដ្ឋានមួយចំនួន ដែលជនជាប់ចោទ ឬពិរុទ្ធជននៅក្នុងបទល្មើសព្រហ្មទណ្ឌណាមួយត្រូវទទួលបាន។

នៅក្នុងអំឡុងពេលនៃការពិភាក្សាជាមួយនឹងប្រធានសាលាឧទ្ធរណ៍[30] លោកប្រធានបានលើកឡើងថាតាមនីតិវិធី បទចោទដោយមានមាត្រាច្បាប់បញ្ជាក់ផង ទីកន្លែង និងកាលបរិច្ឆេទនៃបទល្មើស ព្រមទាំងព័ត៌មានដែលពាក់ព័ន្ធនឹងបទល្មើសត្រូវបានប្រាប់ដល់ជនជាប់ចោទដោយសាលាដំបូងរួចហើយ។ តែយ៉ាងណាក៏ដោយ លោកប្រធានបន្តថា ប្រធានក្រុមប្រឹក្សាជំនុំជម្រះនៅសាលាឧទ្ធរណ៍ក៏នៅតែអានរបាយការណ៍សង្ខេបនៃសំណុំរឿងដែលមានព័ត៌មានដូចបានរៀបរាប់ខាងលើនេះ ដូច្នេះវាជាការល្អដែលសាលាឧទ្ធរណ៍គួរបញ្ជាក់បន្ថែមទៀតអំពីបទចោទ មាត្រាច្បាប់ អង្គហេតុ និងព័ត៌មានដែលពាក់ព័ន្ធ។

### តួលេខទី៤ ៖ ការពន្យល់ប្រាប់សិទ្ធិ

| **ទិន្នន័យ** | **តើចៅក្រមបានប្រាប់ និងពន្យល់ពិរុទ្ធជនពីសិទ្ធិទទួលបានជំនួយពីមេធាវី ឬសិទ្ធិការពារខ្លួនដោយខ្លួនឯងដែរ ឬទេ?** | | **តើចៅក្រមបានប្រាប់ និងពន្យល់ពិរុទ្ធជនពីសិទ្ធិមិននិយាយស្តីដែរ ឬទេ?** | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| ប្រាប់ | ១ | ០,៥ | ១ | ០,៥ |
| ប្រាប់ និងពន្យល់ | ៥ | ២,៥ | ១ | ០,៥ |
| គ្មានប្រាប់ និង គ្មានពន្យល់ | ១៨១ | ៨៩ | ១៨៥ | ៩១ |
| មិនពាក់ព័ន្ធ | ១៧ | ៨ | ១៧ | ៨ |

ដូចតួលេខខាងលើបង្ហាញថា នៅខណៈដែលចៅក្រមនៅសាលាឧទ្ធរណ៍លើកឡើងពីបទចោទ និងអង្គហេតុ ចៅក្រមស្ទើរតែខកខានជាប្រព័ន្ធក្នុងការប្រាប់ពិរុទ្ធជនអំពីសិទ្ធិតាមផ្លូវច្បាប់របស់អ្នកទាំងនោះដោយពុំមានការពន្យល់អ្វីសោះ។ មានតែករណីចំនួន ១ តែប៉ុណ្ណោះក្នុងចំណោមសំណុំរឿងចំនួន ២០៤ ដែលបានសង្កេត ដែលចៅក្រមបានប្រាប់ និងពន្យល់អំពីសិទ្ធិនៅស្ងៀមដល់ពិរុទ្ធជន ឬក្នុងន័យម្យ៉ាងទៀត សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង ឬសារភាពអំពីពិរុទ្ធភាព។ លើសពីនេះទៀត មានតែករណីចំនួន ៥ ក្នុងចំណោមសំណុំរឿង ២០៤ ដែលបានសង្កេត ចៅក្រមបានប្រាប់ និងពន្យល់អំពីសិទ្ធិមានមេធាវី

[30] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងលោក ប៊ុន សាវ៉ាត់ នាយកក្រឡាបញ្ជី នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៤។

ដល់ពិរុទ្ធជន។ សិទ្ធិទាំងនេះនៅតែមានអានុភាពនៅក្នុងនីតិវិធីតុលាការ ហើយហេតុដូច្នេះ គួរតែត្រូវបានរម្លឹកឡើងវិញនៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។ ការអនុវត្តន៍ដែលបណ្តាលឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ពិរុទ្ធជនបែបនេះ អាចត្រូវបានដោះស្រាយយ៉ាងស្រួល។

### ២.១.៣. សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ៖**

- **មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ ៖** *"ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។"*
- **មាត្រា១៤(៣)(ឃ) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ៖** *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយផ្នែកច្បាប់តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិ ប្រសិនបើខ្លួនគ្មានជំនួយផ្នែកច្បាប់ហើយ ត្រូវទទួលបានជំនួយផ្នែកច្បាប់សម្រាប់ខ្លួនក្នុងករណី ដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះបើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយផ្នែកច្បាប់ទេ។"*
- **មាត្រា១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖** *"នៅពេលជនត្រូវចោទដែលជាអនីតិជន ចូលបង្ហាញខ្លួនលើកដំបូង ជននេះត្រូវតែមានមេធាវីអមជានិច្ច។ បើគ្មានការជ្រើសរើសដោយជនត្រូវចោទទេ មេធាវីត្រូវចាត់តាំងនៅក្នុងលក្ខខណ្ឌ ដែលចែងដោយច្បាប់ស្តីអំពីលក្ខន្តិកៈមេធាវី។"*
- **មាត្រា៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖** *"ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរនៅក្នុងលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។"*
- **មាត្រា៣០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖** *"ជំនួយពីមេធាវីត្រូវមានជាដាច់ខាតក្នុងករណីដូចតទៅ ៖ (១)ករណីបទឧក្រិដ្ឋ ឬ (២)កាលណាជនជាប់ចោទជាអនីតិជន។"*
- **មាត្រា៣៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖** *"ជនជាប់ចោទដែលជាប់ឃុំ ត្រូវតែផ្ទេរនៅក្នុងរយៈពេលខ្លីបំផុត តាមបញ្ជារបស់អគ្គព្រះរាជអាជ្ញា ឲ្យទៅនៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួនដែលនៅជិតជាងគេបំផុតនៃទីស្នាក់ការរបស់សាលាឧទ្ធរណ៍"។*
- **មាត្រា៦២ នៃច្បាប់ស្តីពីពន្ធនាគារ ៖** *"ការផ្ទេរជនជាប់ឃុំក្រៅពីទណ្ឌិត ពីពន្ធនាគារមួយទៅពន្ធនាគារមួយ ត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីបញ្ជូន និងព្រះរាជអាជ្ញាមានសមត្ថកិច្ចខាងដែនដីទទួល ឬអគ្គព្រះរាជអាជ្ញាដែលមានសមត្ថកិច្ចកំពុងចាត់ការរឿងក្តី"។* (បកប្រែក្រៅផ្លូវការពីភាសាខ្មែរទៅភាសាអង់គ្លេសដោយ ម.ស.ម.ក)

ការដែលត្រូវចោទប្រកាន់ពីបទល្មើសណាមួយអាចជាបទពិសោធន៍គួរឲ្យខ្លាច ហើយនីតិវិធីច្បាប់អាចមានភាពស្មុគស្មាញ និងច្របូកច្របល់ ហេតុដូច្នោះជាការសំខាន់ណាស់ដែលបុគ្គលគ្រប់រូបមានឱកាសទទួលបានមេធាវី។ សិទ្ធិមានមេធាវីធានាថាពិរុទ្ធជនមានឱកាសក្នុងការទទួលបានការណែនាំផ្នែកវិជ្ជាជីវៈពីអ្នកជំនាញខាងតស៊ូមតិ ដែលមានលទ្ធភាពពន្យល់នូវបទចោទប្រកាន់ប្រឆាំងនឹងខ្លួន ពន្យល់ពីសិទ្ធិ ណែនាំពី

ដំណើរការជំនុំជម្រះ និងការពារផលប្រយោជន៍ដល់ខ្លួននៅក្នុងតុលាការ។ ជាលក្ខខណ្ឌតម្រូវសម្រាប់បុគ្គលម្នាក់ត្រូវទទួលបានមេធាវី ប្រសិនបើបុគ្គលនោះត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ឬក៏ជននោះជាអនីតិជន។ នៅខណៈដែលពុំមានការតម្រូវដោយច្បាប់ចំពោះការទទួលបានមេធាវី ប្រសិនជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទមជ្ឈិម (លើកលែងតែជាអនីតិជន) ជននោះនៅតែមានជម្រើសមានមេធាវី បើខ្លួនត្រូវការ (ទោះបីជាយ៉ាងនេះក្តី បន្ទុកក្នុងការមានមេធាវីពុំស្ថិតលើតុលាការនោះទេ នៅក្នុងករណីបែបនេះ)។

នៅក្នុងអំឡុងពេលនៃការពិភាក្សាជាមួយនឹងប្រធានសាលាឧទ្ធរណ៍[31] លោកប្រធានបញ្ជាក់ថា សិទ្ធិមានមេធាវី និងសិទ្ធិនៅស្ងៀមគួរតែប្រាប់ដល់ពិរុទ្ធជន ដើម្បីធានាដល់ផលប្រយោជន៍នៃយុត្តិធម៌ ដូច្នេះហើយទើបសាលាឧទ្ធរណ៍ខិតខំសហការដើម្បីបិទខិត្តប័ណ្ណនិយាយអំពីសិទ្ធិទាំងនេះ។ ម្យ៉ាងដោយសារតែ បទចោទពីបទឧក្រិដ្ឋ គឺច្បាប់តម្រូវឲ្យមានមេធាវីការពារ តែនៅជាបញ្ហាប្រឈមនៅឡើយចំពោះបទមជ្ឈិម ដោយសារតែការផ្តល់សេវាមេធាវីនៅមានកម្រិត។

## តួលេខទី៥ ៖ សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ

| ទិន្នន័យ | មាន | | គ្មាន | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| តើពិរុទ្ធជនមានវត្តមាននៅពេលសវនាការដែរឬទេ? | ២២០ | ៨២ | ៥០ | ១៨ |
| តើពិរុទ្ធជនមានមេធាវីការពារដែរឬទេក្នុងបទឧក្រិដ្ឋ? | ១៩៨ | ១០០ | ០ | ០ |
| តើពិរុទ្ធជនមានមេធាវីការពារដែរឬទេបទមជ្ឈិម? | ៨២ | ៦៧ | ៤០ | ៣៣ |

* ទិន្នន័យនេះផ្អែកលើចំនួនពិរុទ្ធជនសរុប (ចំនួន ២៧០ នាក់) ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៤ ដែលបានសង្កេត។

តួលេខនេះបង្ហាញថា មានចំនួន ១៨% ដែលពិរុទ្ធជនពុំមានវត្តមាននៅពេលសវនាការជំនុំជម្រះ និងចំនួន ៣៣% មិនមានមេធាវីការពារក្នុងបទមជ្ឈិម។ ប្រការរឹតតែគួរឲ្យព្រួយបារម្ភជាងនេះទៀត គឺថាពិរុទ្ធជនចំនួន ១៥ នាក់ នៅក្នុងសំណុំរឿងចំនួន ១២ ករណី សវនាការប្រព្រឹត្តទៅដោយពុំមានវត្តមានទាំងពិរុទ្ធជន និងមេធាវី។ ក្នុងចំណោម ១២ ករណីនេះ មានតែមួយករណីគត់ដែលបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី ដែលថាករណីបែបនេះមិនប៉ះពាល់ដល់ទោសពន្ធនាគារដែលពិរុទ្ធជនទទួលរង។ ក៏ប៉ុន្តែ ១១ ករណីទៀត គឺបណ្តឹងឧទ្ធរណ៍ត្រូវបានធ្វើឡើងដោយពិរុទ្ធជន (ចំនួន ៨ ករណី) និងព្រះរាជអាជ្ញា (ចំនួន ៣ ករណី) ប្តឹងប្រឆាំងសាលក្រមទាំងមូលដែលអាចនាំឲ្យប្រែប្រួលដល់ទោសពន្ធនាគារ។ ករណីបែបនេះគឺជាការរំលោភបំពានធ្ងន់ធ្ងរដល់សិទ្ធិរបស់បុគ្គលក្នុងការការពារខ្លួន និងសមភាពនៃការតទល់គ្នាតាមផ្លូវច្បាប់នៅក្នុងនីតិវិធីសវនាការជំនុំជម្រះ។

[31] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងលោក ប៊ុន សាវ៉ាត់ នាយកក្រឡាបញ្ជី នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៤។

អវត្តមានរបស់ពិរុទ្ធជន ជារឿយៗកើតឡើងដោយសារតែបញ្ហាផ្នែកភស្តុភារ និងការប្រាស្រ័យទាក់ទងរវាងចៅក្រម និងមណ្ឌលអប់រំកែប្រែ/មន្ទីរឃុំខ្លួន។ ហេតុម្យ៉ាងដោយថា មានតែសាលាឧទ្ធរណ៍តែមួយប៉ុណ្ណោះនៅទូទាំងប្រទេស តម្រូវឲ្យពិរុទ្ធជនដែលត្រូវបានឃុំខ្លួននៅមណ្ឌលអប់រំកែប្រែនៅតាមបណ្ដាខេត្តត្រូវធ្វើដំណើរទៅសាលាឧទ្ធរណ៍ដើម្បីចូលរួមសវនាការជំនុំជម្រះ។ ទោះបីជាយ៉ាងនេះក្ដី ករណីដឹកជញ្ជូនពិរុទ្ធជនមួយចំនួនមិនបានធ្វើទេ ដោយសារតែតុលាការផ្ញើព័ត៌មានទៅមណ្ឌលអប់រំកែប្រែខុស ពីព្រោះមណ្ឌលអប់រំកែប្រែនោះខកខានក្នុងការផ្ដល់ព័ត៌មានបច្ចុប្បន្នភាពអំពីការផ្ទេរជនជាប់ឃុំនៅក្នុងចំណោមមណ្ឌលអប់រំកែប្រែខ្លួនឯង។ បញ្ហាផ្នែកភស្តុភារនេះអាចត្រូវបានដោះស្រាយដោយងាយ មិនត្រឹមតែតាមរយៈការបង្កើតសាលាឧទ្ធរណ៍បន្ថែមទៀតប៉ុណ្ណោះទេ តែថែមទាំងតាមរយៈការធ្វើឲ្យប្រសើរឡើងនូវការរក្សាទុកកំណត់ត្រា និងការប្រាស្រ័យទាក់ទងរវាងតុលាការ និងមណ្ឌលអប់រំកែប្រែនានា។

លើសពីនេះទៀត បញ្ហានៃការប្រាស្រ័យទាក់ទង និងអវត្តមានរបស់ពិរុទ្ធជន ជាញឹកញាប់ធ្វើឲ្យមានការពន្យារពេលសវនាការដោយមិនចាំបាច់ ដែលតម្រូវឲ្យចៅក្រមត្រូវផ្អាកសវនាការជំនុំជម្រះ។ យោងតាមទិន្នន័យរបស់ ម.ស.ម.ក សាលាឧទ្ធរណ៍បានគ្រោងបើកសវនាការជំនុំជម្រះចំនួន ៨៣៨ សំណុំរឿងចាប់ពីខែមេសា ឆ្នាំ២០១៣ ដល់ខែមករា ឆ្នាំ២០១៤។ ក្នុងចំណោមសំណុំរឿងទាំង ៨៣៨ សំណុំរឿងចំនួន ៣៣២ (ឬស្មើនឹង ៤០% នៃសំណុំរឿងដែលបានគ្រោង) ត្រូវបានលើកពេលជំនុំជម្រះទៅកាលបរិច្ឆេទក្រោយទៀត។ ហេតុផលនៃការពន្យារពេលសវនាការជំនុំជម្រះមានខុសៗគ្នា និងអាចមកពីមេធាវីបានស្នើសុំឲ្យពន្យារសវនាការ ពិរុទ្ធជនមិនយល់ព្រមទទួលយកមេធាវីដែលបានចាត់តាំងឲ្យ ពុំមានមេធាវីការពារក្នុងសំណុំរឿងបទឧក្រិដ្ឋ ឬពិរុទ្ធជនអវត្តមាន ជាដើម។ អវត្តមានរបស់ពិរុទ្ធជនជាហេតុផលដ៏ចម្បងសម្រាប់ការពន្យារពេលក្នុងចន្លោះពីខែកញ្ញា ឆ្នាំ២០១៣ ដល់ខែមករា ឆ្នាំ២០១៤ (រយៈពេលជាងប្រាំខែ) មានសវនាការចំនួន ៤៥% ត្រូវបានពន្យារដោយសារតែអវត្តមានពិរុទ្ធជន។

នៅក្នុងអំឡុងពេលនៃការពិភាក្សាជាមួយនឹងប្រធានសាលាឧទ្ធរណ៍[32] លោកប្រធានលើកឡើងថា ករណីដែលអាចអវត្តមានទាំងពិរុទ្ធជន និងមេធាវីអាចបណ្ដាលមកពីកត្តាមួយចំនួនដូចជា ៖ (១) សំណុំរឿងខ្លះពិរុទ្ធជននៅក្រៅឃុំ ហើយមិនចូលខ្លួននៅពេលសវនាការ (២) ករណីខ្លះជាសំណុំរឿងតូចតាច ហើយពិរុទ្ធជនមិនរកមេធាវីការពារ និង (៣) ការផ្លាស់ប្ដូរទីតាំងឃុំខ្លួនពិរុទ្ធជន និងការបញ្ជូនដីកាកោះមួយចំនួនមិនអាចធ្វើទៅកើតដោយសារតែប្រព័ន្ធនៃការបញ្ជូននៅមានបញ្ហាស្មុគ្រស្មាញ។ លោកប្រធានបន្តទៀតថា ដោយសារតែបញ្ហាទាំងនេះហើយ ដែលជំរុញឲ្យសាលាឧទ្ធរណ៍ត្រូវពិចារណាថ្លឹងថ្លែងថា ប្រសិនជាទុកសំណុំរឿងយូរ ឬអូសបន្លាយសវនាការទៀត អាចនឹងប៉ះពាល់ដល់សិទ្ធិរបស់ពិរុទ្ធជនថែមទៀត។

---

[32] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងលោក ប៉ុន សាវ៉ាត់ នាយកក្រឡាបញ្ជី នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៤។

## ២.១.៤. សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ៖**

- **មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ៖** *"ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។"*
- **មាត្រា១៤(២) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ៖***"ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌត្រូវបានសន្មតជាមុនថាជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួនត្រូវបានកំណត់ស្របតាមច្បាប់។"*

ការសន្មតទុកជាមុនថាគ្មានទោស ឬសច្ចធារណ៍នៃនិរទោស គឺជាសិទ្ធិមូលដ្ឋាន និងត្រូវបានទទួលស្គាល់ជាសកលថាជាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលសិទ្ធិនេះអនុវត្តនៅពេញនីតិវិធីនៃការស៊ើបអង្កេតផ្នែកព្រហ្មទណ្ឌ និងជំនុំជម្រះ រហូតដល់ការបញ្ចប់បណ្តឹងឧបាស្រ័យចុងក្រោយ។[33] សច្ចធារណ៍នេះឆ្លុះបញ្ចាំងពីគោលការណ៍ដែលថា បន្ទុកនៃភស្តុតាងស្ថិតនៅលើស្ថាប័នអយ្យការ មិនមែនជាបន្ទុករបស់ពិរុទ្ធជនទេ ដូច្នេះ តុលាការត្រូវជឿជាក់ថាភស្តុតាងដែលបានលើកឡើងត្រូវបង្ហាញពីពិរុទ្ធភាពរបស់ពិរុទ្ធជនហួសពីវិមតិសង្ស័យ។ នេះពុំមែនអាស្រ័យលើពិរុទ្ធជនក្នុងការបង្ហាញនូវភស្តុតាងដើម្បីបង្ហាញថា ខ្លួនជាជនគ្មានទោសនោះឡើយ។

### តួលេខទី៦ ៖ សិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោស

| ទិន្នន័យ | មាន | | គ្មាន | | មិនពាក់ព័ន្ធ[34] | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| តើពិរុទ្ធជនស្លៀកពាក់ឯកសណ្ឋានជាអ្នកទោសនៅពេលសវនាការដែរឬទេ? | ១៤០ | ៥២ | ៨០ | ៣០ | ៥០ | ១៨ |
| តើពិរុទ្ធជនត្រូវបានដាក់ខ្នោះក្នុងពេលសវនាការដែរឬទេ? | ០ | ០ | ២២០ | ៨២ | ៥០ | ១៨ |
| តើចៅក្រមបាននិយាយពីពិរុទ្ធភាពរបស់ពិរុទ្ធជន មុនពេលប្រកាសសាលដីកាដែរឬទេ? | ០ | ០ | ២៧០ | ១០០ | ០ | ០ |

* ទិន្នន័យនេះផ្អែកលើចំនួនពិរុទ្ធជនសរុប (ចំនួន ២៧០ នាក់) ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៤ ដែលបានសង្កេត។

---

[33] ការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស, សៀវភៅណែនាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ភាគទី១, ជំពូកទី៦, ទំព័រទី២១៩, http://bit.ly/1jp0Xxn ។

[34] មិនពាក់ព័ន្ធសំដៅទៅលើករណីដែលពិរុទ្ធជនពុំមានវត្តមាននៅពេលសវនាការ។

នៅពេលដែលពិរុទ្ធជនចូលរួមសវនាការដោយឯកសណ្ឋានពន្ធនាគារ សច្ចធារណ៍នៃនិរទោសត្រូវបានប៉ះពាល់ជាខ្លាំង នៅពេលដែលឯកសណ្ឋាននោះពុំបង្ហាញពីភាពខុសគ្នារវាងអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការ និងទណ្ឌិត។ នៅពេលដែលអ្នកត្រូវបានឃុំខ្លួនរង់ចាំសវនាការចូលទៅតុលាការជាឯកសណ្ឋានពន្ធនាគារ ពួកគេត្រូវបានបង្ហាញក្នុងវិធីដូចគ្នានឹងអ្នកទោសដែលប្រហែលជាត្រូវបានផ្តន្ទាទោស និងកាត់ទោសរួចហើយពាក់ព័ន្ធនឹងបុគ្គល និងបទល្មើសមិនទាក់ទិនគ្នាមួយផ្សេងទៀត។ ដោយសារតែពុំមានភាពខុសគ្នាត្រូវបានបញ្ជាក់រវាងប្រភេទទាំងពីរនេះរបស់អ្នកជាប់ឃុំ ការអនុវត្តន៍បែបនេះធ្វើឲ្យមានការសន្មតយ៉ាងជាក់ស្តែងថា ពិរុទ្ធជនគឺពិតជាជនល្មើសដែលត្រូវបានផ្តន្ទាទោសរួចហើយ ហេតុដូច្នេះ អាចជះឥទ្ធិពលដល់សេចក្តីសម្រេចរបស់ចៅក្រម។ សូម្បីតែនៅពេលពិរុទ្ធជនកំពុងតែជាប់ឃុំ ហេតុដែលថាពិរុទ្ធជនទាំងនោះបង្ហាញខ្លួននៅចំពោះមុខតុលាការក្នុងឯកសណ្ឋានពន្ធនាគារ គឺធ្វើឲ្យប៉ះពាល់ដល់ប្រយោជន៍យុត្តិធម៌ដូចគ្នាដែរ។ ពាក់ព័ន្ធនឹងឯកសណ្ឋានរបស់ពិរុទ្ធជននេះគឺមិនមែនជាការទទួលខុសត្រូវរបស់សាលាឧទ្ធរណ៍ទេ តែជាការទទួលខុសត្រូវរបស់អគ្គនាយកដ្ឋានពន្ធនាគារ។

តួលេខខាងលើបង្ហាញថា នៅតែជាការអនុវត្តន៍ជាទូទៅ (ចំនួន ៥២%) ដែលពិរុទ្ធជនបង្ហាញខ្លួនក្នុងឯកសណ្ឋានជាអ្នកទោសនៅក្នុងពេលសវនាការ។ ការអនុវត្តន៍បែបនេះធ្វើឲ្យអន់ថយដល់គោលការណ៍សន្មតទុកជាមុនថាគ្មានទោស។

## ២.១.៥. សិទ្ធិបង្ហាញភស្តុតាង

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ៖**

- **មាត្រា១៤(៣)(ង) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ៖** *"ជនគ្រប់រូបមានសិទ្ធិ [...] មានការសួរចម្លើយ ឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យសាក្សីដោះបន្ទុកចូលខ្លួនដើម្បីសួរចម្លើយក្នុងនាមខ្លួនក្នុងលក្ខខណ្ឌដូចគ្នានឹងសាក្សីដាក់បន្ទុក។"*
- **មាត្រា១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖** *"ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលចម្លើយនោះអាចមានប្រយោជន៍ក្នុងការសំដែងឲ្យឃើញការពិត [...] ចៅក្រមស៊ើបសួរក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ [...] និងសាក្សីផងបានដែរ។"*
- **មាត្រា២៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖** *"ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចនាំចូលរួមក្នុងសវនាការនូវសាក្សីទាំងឡាយណា ដែលព្រះរាជអាជ្ញាមិនបានកោះហៅដោយខ្លួនជាអ្នកចេញសោហ៊ុយ។"*
- **មាត្រា៣២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖** *"នៅពេលបើកពិភាក្សាដេញដោល ភាគីអាចសុំឲ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គល ដែលមានវត្តមាននៅក្នុងបន្ទប់ ប៉ុន្តែមិនកោះហៅឲ្យត្រឹមត្រូវទេ។ ការស្តាប់ចម្លើយសាក្សីនេះត្រូវមានការយល់ព្រមពីប្រធានសវនាការ។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះឲ្យថយទៅនៅក្នុងបន្ទប់រង់ចាំ។"*
- **មាត្រា៣២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖** *"ប្រធានសវនាការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកជំនាញតាមលំដាប់លំដោយ ដែលខ្លួនយល់ថាមានប្រយោជន៍ [...] ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានឲ្យលើកសំណួរសួរ។ គ្រប់ការ*

*លើកសំណួរទាំងអស់ត្រូវតែបានការអនុញ្ញាតពីប្រធានសវនាការ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវីសំណួរផ្សេងទៀត ត្រូវសួរតាមរយៈប្រធានសវនាការ។ ក្នុងករណីមានការតវ៉ា ប្រធានសវនាការសម្រេចដោយឥស្សរចិត្តថាតើសំណួរនេះត្រូវតែសួរ ឬទេ។"*

- **មាត្រា៣៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ៖** *"ក្រោយពេលសួរចម្លើយជនជាប់ចោទរួច ប្រធានស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី តាមលំដាប់លំដោយដែលខ្លួនយល់ឃើញថាមានប្រយោជន៍។"*

រាល់សេចក្តីសម្រេចទាំងអស់របស់តុលាការត្រូវតែផ្អែកទាំងស្រុងលើភស្តុតាង ដែលបានបង្ហាញនៅក្នុងដំណាក់កាលនៃការជំនុំជម្រះ។ ដូច្នេះ ជាការសំខាន់ដែលភាគីនីមួយៗមានឱកាសដើម្បីបង្ហាញនូវភស្តុតាង និងហៅសាក្សីនានាជាការគាំទ្រទៅលើសំណុំរឿងរបស់ខ្លួន។[35] ជាការចាំបាច់ដូចគ្នា ដែលភាគីនីមួយៗត្រូវបានផ្តល់ឱកាស ដើម្បីសួរដេញដោលសាក្សី និងបដិសេធនូវភស្តុតាងដែលខ្លួនមិនទទួលយក។ ជាការគួរឲ្យលើកទឹកចិត្ត និងការកត់សម្គាល់ពីភាពវិជ្ជមាន ដោយសារតែទិន្នន័យដែលប្រមូលបានបង្ហាញថា ពុំមានអ្វីដែលសម្តែងឲ្យឃើញថាភាគីណាមួយពុំត្រូវបានផ្តល់ឱកាសឲ្យកោះហៅសាក្សីនៅក្នុងសំណុំរឿងសរុបទាំង ២០៤ នោះទេ។

ទោះជាយ៉ាងណាក៏ដោយ សិទ្ធិបង្ហាញភស្តុតាងនៅតែជាបញ្ហាប្រឈមដ៏គ្រោះថ្នាក់ក្នុងហេតុផលពីរយ៉ាង។ អ្នកសង្កេតការណ៍បានកត់សម្គាល់ឃើញថា មានសំណុំរឿងតិចតួចណាស់ដែលសាក្សីមានវត្តមានផ្ទាល់នៅពេលសវនាការ (ចំនួន ១៤ ករណីក្នុងចំណោមសំណុំរឿងសរុប ២០៤) ហើយភាគច្រើន (ចំនួន ៦ ករណីក្នុងចំណោម ១៤ សំណុំរឿង) សាក្សីមានវត្តមាននៅក្នុងបន្ទប់សវនាការមុនពេលសាក្សីនោះត្រូវបានហៅសាកសួរ។ ការអនុវត្តន៍ដែលប្រសើរសម្រាប់សាក្សី គឺត្រូវឲ្យសាក្សីនោះចាកចេញពីបន្ទប់សវនាការ និងមិនត្រូវត្រលប់ទៅបន្ទប់សវនាការ រហូតទាល់តែសាក្សីនោះត្រូវបានហៅឲ្យផ្តល់សក្ខីកម្ម ដែលជានីតិវិធីមួយដើម្បីធានាថា សាក្សីទាំងនោះពុំទទួលរងនឹងឥទ្ធិពលណាមួយតាមរយៈភស្តុតាង និងសក្ខីកម្មផ្សេងទៀតដែលបង្ហាញនៅក្នុងពេលសវនាការជំនុំជម្រះ។

លើសពីនេះទៀត ស្របពេលដែលជាការគួរឲ្យលើកទឹកចិត្តដោយឃើញថា តុលាការបន្តស្វែងរកភស្តុតាងនៅក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការជំនុំជម្រះ សាលាឧទ្ធរណ៍ក៏ត្រូវតែធានាថា ភស្តុតាងដែលត្រូវយកមកថ្លឹងថ្លែងមានគុណភាពគ្រប់គ្រាន់ និងធានាថា ភាគីទាំងអស់មានឱកាសក្នុងការជំទាស់នឹងភស្តុតាងនោះ។ ទិន្នន័យដែលបានប្រមូលនៅក្នុងអំឡុងពេលនៃសកម្មភាពសង្កេតការណ៍សវនាការបង្ហាញថា គុណភាពនៃភស្តុតាងដែលបានបង្ហាញគឺជាប្រការគួរឲ្យព្រួយបារម្ភ។ ភស្តុតាងភាគច្រើនដែលបានបង្ហាញនៅសវនាការដែលបានសង្កេត គឺជាការសារភាព ឬភស្តុតាងជាឯកសារ។ គុណភាព និងចំនួននៃភស្តុតាងដែលបានបង្ហាញ និងថ្លឹងថ្លែងក្នុងអំឡុងពេលសវនាការជំនុំជម្រះ គឺមានភាពចាំបាច់ដើម្បីធានាថា បុគ្គលគ្រប់រូបត្រូវបានតុលាការរកឃើញពីពិរុទ្ធភាពហួសពីវិមតិសង្ស័យ។ បន្ថែមពីលើភស្តុតាងជាឯកសារ ចៅក្រម និង

[35] មាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ព្រះរាជអាជ្ញាគួរតែមានភាពសកម្មក្នុងការស្វែងរក និងពិនិត្យប្រភេទនៃភស្តុតាង ដែលពាក់ព័ន្ធ ដូចជា សាក្សីផ្ទាល់ វេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ ជាអាទិ៍។

នៅក្នុងអំឡុងពេលនៃការពិភាក្សាជាមួយនឹងប្រធានសាលាឧទ្ធរណ៍[36] លោកប្រធានបញ្ជាក់ថា សាលាឧទ្ធរណ៍ជាតុលាការអង្គហេតុ និងអង្គច្បាប់ ដូច្នេះ ការបង្ហាញខ្លួនរបស់សាក្សី ឬការបន្ថែមភស្តុតាងថ្មី ដើម្បីធ្វើការតទល់គ្នាជាការចាំបាច់ ក៏ប៉ុន្តែលោកប្រធានគូសបញ្ជាក់ថា ទោះបីជាសាលាឧទ្ធរណ៍បានខិតខំច្រើនណាស់មកហើយ តែស្ថានភាពនាពេលបច្ចុប្បន្នេះនេះនៅមានការលំបាកក្នុងការអនុវត្តន៍ជាក់ស្តែង ប្រសិនជាត្រូវរង់ចាំឲ្យមានការបង្ហាញខ្លួនសាក្សីទាំងអស់។ បញ្ហាលំបាកមានដូចជា ៖ (១) ប្រព័ន្ធនៃការបញ្ជូនដីកាកោះនៅមានភាពយឺតយ៉ាវ (២) សាក្សីមួយចំនួនពុំមានអាសយដ្ឋានច្បាស់លាស់ និង (៣) សាក្សីមួយចំនួនដែលបានឆ្លើយម្តងហើយ ពុំមានចិត្តចង់មកឆ្លើយម្តងទៀត។ បញ្ហាទាំងអស់នេះជាការប្រឈមរបស់សាលាឧទ្ធរណ៍ ដែលសាលាឧទ្ធរណ៍មិនអាចពន្យារសវនាការយូរទៀតបាន ដើម្បីរង់ចាំវត្តមានសាក្សីទាំងអស់នោះទេ ព្រោះថាសាលាឧទ្ធរណ៍ត្រូវថ្លឹងថ្លែងផលប៉ះពាល់នៃការពន្យារដែលអាចនាំឲ្យប៉ះពាល់ដល់សិទ្ធិរបស់ពិរុទ្ធជនផងដែរ។

## ២.១.៦. សិទ្ធិទទួលបានការប្រកាសសេចក្តីសម្រេចជាសាធារណៈ និងមានសម្អាងហេតុច្បាស់លាស់

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ៖**

- **មាត្រា១៤(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ** ៖ *"[...] ប៉ុន្តែ ការចេញសាលក្រមទាំងអស់អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជនតម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។"*
- **មាត្រា៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖*"នៅក្នុងគ្រប់ករណីទាំងអស់ សាលក្រមត្រូវតែប្រកាសនៅពេលសវនាការជាសាធារណៈ។"*

សិទ្ធិទទួលបានសេចក្តីសម្រេចដោយមានសម្អាងហេតុច្បាស់លាស់ នៅជាប់ជាមួយនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងត្រូវបានរួមបញ្ចូលនៅក្នុងសិទ្ធិទទួលបានការប្រកាសសាលដីកានៅពេលសវនាការជាសាធារណៈ។ យោងតាមបទដ្ឋានអន្តរជាតិ ពិរុទ្ធជនមានសិទ្ធិទទួលបាននូវសាលក្រម ឬសាលដីកាជាលាយលក្ខណ៍អក្សរក្នុងរយៈពេលមួយសមរម្យ ហើយសេចក្តីសម្រេចនេះត្រូវមានសម្អាងហេតុត្រឹមត្រូវក្នុងគ្រប់ករណីទាំងអស់ ដើម្បីឲ្យពិរុទ្ធជននោះអនុវត្តសិទ្ធិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពក្នុងការស្នើឲ្យតុលាការជាន់ខ្ពស់ពិនិត្យពីការចោទប្រកាន់ និងការផ្តន្ទាទោសរបស់ខ្លួនដោយផ្អែកលើច្បាប់។[37]

---

[36] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ឯកឧត្តម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងលោក ប៉ុន សាវ៉ាត់ នាយកក្រឡាបញ្ជី នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៤។

[37] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីសម្រេចលេខ ៣២០/១៩៨៨, *វី ហ្វ្រង់ស៊ីស ទល់នឹង ប្រទេសចាម៉ៃកា* (ទស្សនៈនេះត្រូវបានអនុម័តនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩៣) នៅក្នុងឯកសាររបស់ អ.ស.ប លេខ GAOR, ក/៤៨/៤០ (លេខពីរ), ទំព័រទី៦៦ កថាខណ្ឌទី១២.២, http://bit.ly/1gfuZQw ។

### តួលេខទី៧ ៖ សាលដីការបស់សាលាឧទ្ធរណ៍

| ទិន្នន័យ | មានពិរុទ្ធភាព | | គ្មានពិរុទ្ធភាព | | ស៊ើបអង្កេតឡើងវិញ | | មិនដឹង | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| តើតុលាការសម្រេចសេចក្ដីយ៉ាងដូចម្ដេច? | ២៤០ | ៨៩ | ២៦ | ១០ | ៤ | ១ | ០ | ០ |

* ទិន្នន័យនេះផ្អែកលើចំនួនពិរុទ្ធជនសរុប (ចំនួន ២៧០ នាក់) ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៤ ដែលបានសង្កេត។

### តួលេខទី៨ ៖ សិទ្ធិទទួលបានសាលដីកាដោយមានសម្អាងហេតុច្បាស់លាស់

| ទិន្នន័យ | មាន | | គ្មាន | | មិនពាក់ព័ន្ធ | |
|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % |
| តើសាលដីកាត្រូវបានប្រកាសជាសាធារណៈដែរឬទេ? | ២០៤ | ១០០ | ០ | ០ | ០ | ០ |

* ទិន្នន័យនេះផ្អែកលើចំនួនពិរុទ្ធជនសរុប (ចំនួន ២៧០ នាក់) ដែលជាប់ពាក់ព័ន្ធនឹងសំណុំរឿងចំនួន ២០៤ ដែលបានសង្កេត។

ជាចំណុចវិជ្ជមានដែលសម្គាល់ឃើញថាតួលេខខាងលើនេះបង្ហាញថា ករណីទាំងអស់ដែលព័ត៌មានអាចរកបាន គឺថាសិទ្ធិទទួលបានសេចក្ដីសម្រេចជាសាធារណៈត្រូវបានគោរព។ ប៉ុន្តែ អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក នៅតែសង្កេតឃើញថា ចៅក្រមមិនបានយោងមាត្រានៃច្បាប់ ឬភស្តុតាងដែលបានបង្ហាញក្នុងពេលសវនាការជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍នៅក្នុងសាលដីការបស់ខ្លួននោះទេនៅក្នុងករណីជាច្រើន។ ទោះបីជាសាលាឧទ្ធរណ៍តម្កល់សាលក្រមរបស់សាលាដំបូងយ៉ាងណាក្ដី ក៏សាលាឧទ្ធរណ៍ត្រូវតែពន្យល់នៅពេលអានសេចក្ដីសម្រេចឲ្យច្បាស់អំពីមូលហេតុដែលនាំឲ្យខ្លួនសម្រេចយ៉ាងដូច្នោះ។ ករណីបែបនេះ គឺជាការរំលោភបំពានជាក់ស្ដែងទៅលើសិទ្ធិទទួលបានសាលដីកាដោយមានសម្អាងហេតុច្បាស់លាស់ ហើយហេតុដូច្នេះ ក៏ជាការបំពានលើធាតុផ្សំដ៏សំខាន់នៃសិទ្ធិទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ដោយតុលាការឯករាជ្យ ព្រមទាំងធ្វើឲ្យមានមន្ទិលសង្ស័យលើភាពឥតលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រមនៅសាលាឧទ្ធរណ៍។ ហេតុដូច្នេះ ម.ស.ម.ក អាចត្រឹមតែលើកទឹកចិត្តឲ្យចៅក្រមទាំងឡាយនៅសាលាឧទ្ធរណ៍ធ្វើការផ្លាស់ប្ដូរការអនុវត្តន៍របស់ខ្លួន ដើម្បីជម្រះនូវមន្ទិលសង្ស័យទាំងឡាយជុំវិញភាពឥតលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រម។

## ២.១.៧. ឯករាជ្យភាព ភាពឥតលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រម

**ប្រភពនៅក្នុងច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ៖**

- **មាត្រា១២៨ នៃរដ្ឋធម្មនុញ្ញ ៖** *"អំណាចតុលាការជាអំណាចឯករាជ្យ។ អំណាចតុលាការធានារក្សាអនាគតិ និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ។"*
- **មាត្រា១៣២ នៃរដ្ឋធម្មនុញ្ញ ៖** *"ព្រះមហាក្សត្រទ្រង់ជាអ្នកធានាឯករាជ្យនៃអំណាចតុលាការ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជួយព្រះមហាក្សត្រក្នុងកិច្ចការនេះ។"*
- **មាត្រា១៤ (១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ៖** *"ក្នុងការសម្រេចផ្តន្ទាទោសឧក្រិដ្ឋទៅលើជនណាម្នាក់ និង ក្នុងការសម្រេចអំពីសិទ្ធិ និង កាតព្វកិច្ចរបស់ជនណាម្នាក់ក្នុងករណីមានការប្តឹងផ្តល់សាមីខ្លួនត្រូវមានសិទ្ធិស្នើសុំឲ្យមានការកាត់សេចក្តីឲ្យបានសមរម្យជាសាធារណៈ ដោយសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀងដែលបង្កើតឡើងដោយច្បាប់។"*

សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការឯករាជ្យ និងមិនលម្អៀងគឺជាគ្រឹះធំមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។ ពិរុទ្ធជនត្រូវជំនុំជម្រះដោយផ្អែកលើភាពសត្យានុម័ត។ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នេះ ត្រូវបានគណៈកម្មាធិការសិទ្ធិមនុស្សរបស់ អ.ស.ប អធិប្បាយថាជា *"សិទ្ធិមួយដាច់ខាត គ្មានករណីលើកលែង"*។[38] ប្រាកដណាស់ ប្រសិនបើតុលាការពុំឯករាជ្យ ឬលម្អៀង ដូច្នេះ រាល់សិទ្ធិទទួលបានការជំនុំជម្រះដទៃៗទៀតក្លាយទៅជាឥតប្រយោជន៍។ តុលាការដែលទទួលរង និងទទួលឥទ្ធិពលពីប្រភពខាងក្រៅពុំមានសមត្ថភាពក្នុងការបំពេញតួនាទីរបស់ខ្លួន ដើម្បីធានាឲ្យមានការជំនុំជម្រះដោយយុត្តិធម៌នោះទេ។

បើទោះជាករណី ដែលភាគីដទៃទៀតអាចមានឱកាសក្នុងការនិយាយទៅកាន់ចៅក្រមក្នុងអំឡុងពេលកិច្ចពិភាក្សាជារឿងដ៏កម្រក៏ដោយ ជាប្រការសំខាន់ដែលថា ករណីបែបនេះគួរតែត្រូវលុបបំបាត់ចោលទាំងស្រុង។ ខណៈដែលទិន្នន័យរបស់ ម.ស.ម.ក ប្រមូលបាន ពុំបង្ហាញច្បាស់លាស់ថា មានករណីណាខ្លះមានការជ្រៀតជ្រែកនៅក្នុងកិច្ចពិភាក្សាណាមួយនោះ ចៅក្រមត្រូវតែធានាថា ការប្រព្រឹត្តរបស់ខ្លួនមិនត្រូវធ្វើឲ្យមានការយល់ឃើញថាករណីបែបនេះអាចកើតឡើងនោះឡើយ។

**ករណីសិក្សា ៖ សវនាការជំនុំជម្រះលើសំណុំរឿងរបស់លោក ឈូក បណ្ឌិត[39]**

**កាលបរិច្ឆេទ ៖ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣**

---

[38] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្តីជូនដំណឹងលេខ២៦៣/១៩៨៧ ៖ *អឹម ហ្គន់ហ្សាឡេសដេលរីយ៉ូ តទល់នឹង ប្រទេស ប៉េរូ* (CCPR/គ/៤៦/ឃ/២៦៣/១៩៨៧), ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩២, កថាខណ្ឌទី៥.២, http://bit.ly/1h33UDx ។

[39] ម.ស.ម.ក, "ការវិភាគផ្លូវច្បាប់លើសំណុំរឿងព្រហ្មទណ្ឌប្រឆាំងនឹងអតីតអភិបាលក្រុងបាវិតលោក ឈូក បណ្ឌិត និងនាយនគរបាលលោក ស ចន្ថា ក្នុងករណីបាញ់ប្រហារលើកម្មការិនីរោងចក្រកៅវ៉េ កាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២", (ការវិភាគផ្នែកច្បាប់), ខែវិច្ឆិកា ឆ្នាំ២០១៣, http://bit.ly/1dkxtgh។

**តុលាការ ៖ សាលាឧទ្ធរណ៍រាជធានីភ្នំពេញ**

**ចៅក្រម ៖ លោក តាំង ស៊ុនឡាយ (ប្រធានក្រុមប្រឹក្សា) លោក ប្លង់ សំណាង និងលោក អ៊ុំ សារីទ្ធ**

**បទចោទ ៖** មាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ "បទបង្កឲ្យរបួសដោយអចេតនា"។ បទចោទនេះធ្វើឡើងដោយផ្អែកលើការចោទប្រកាន់ដែលថា លោក ឈូក បណ្ឌិត បានប្រើកាំភ្លើងបាញ់ទៅលើក្រុមបាតុករនៅរោងចក្រកាត់ដេរ *កៅវ៉េ ស្ពត លីមីតធីត* នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១២ ដែលបានបណ្តាលឲ្យកម្មការិនីចំនួន ៣ នាក់បានរងរបួសធ្ងន់ រួមមានឈ្មោះ កែវ នា អាយុ ១៩ ឆ្នាំ ប៊ុន ចិន្តា អាយុ ២១ ឆ្នាំ និង នុត សាខន អាយុ ២៣ ឆ្នាំ។

**សារតារ ៖** នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១២ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តស្វាយរៀង បានបញ្ជាក់ថា លោក ឈូក បណ្ឌិត ដែលជាអតីតអភិបាលក្រុងបាវិត ត្រូវបានអយ្យការធ្វើការសាកសួរ និងបានសារភាពថាខ្លួនបានបាញ់ស្ត្រីទាំងបីនាក់នោះមែន ប៉ុន្តែពុំបានបញ្ជាក់ពីហេតុផលដែលនាំឲ្យមានការបាញ់ប្រហារនោះទេ។ ទោះជាយ៉ាងនេះក្តី ព្រះរាជអាជ្ញាពុំបានស្នើឲ្យចាត់វិធានការឃុំខ្លួនបណ្តោះអាសន្នលោក ឈូក បណ្ឌិត នោះទេ ហើយនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ សាលាដំបូងខេត្តស្វាយរៀងបានទម្លាក់ចោលបទចោទប្រកាន់ប្រឆាំងនឹងលោក ឈូក បណ្ឌិត ដោយពុំបានផ្តល់ការពន្យល់ណាមួយចំពោះសេចក្តីសម្រេចរបស់ខ្លួននោះទេ។

នៅថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៣ បន្ទាប់ពីសវនាការបិទទ្វារពិចារណាលើភស្តុតាងរយៈពេល ២ ថ្ងៃ ដែលលោក ឈូក បណ្ឌិត បានចូលរួមផងនោះ សភាស៊ើបសួរនៃសាលាឧទ្ធរណ៍បានសម្រេចចោទប្រកាន់ឡើងវិញចំពោះលោក ឈូក បណ្ឌិត។ សំណុំរឿងរបស់លោក ឈូក បណ្ឌិត ត្រូវបានសាលាដំបូងខេត្តស្វាយរៀងវិនិច្ឆ័យសេចក្តីឡើងវិញដោយកំបាំងមុខជនជាប់ចោទ ក្នុងខែមិថុនា ឆ្នាំ២០១៣។ នៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ សាលាដំបូងខេត្តស្វាយរៀងបានរកឃើញពីពិរុទ្ធភាពរបស់លោក ឈូក បណ្ឌិត ពី"បទបង្កឲ្យមានរបួសដោយអចេតនា" ហើយត្រូវបានតុលាការសម្រេចផ្តន្ទាទោសពន្ធនាគាររយៈពេល ១៨ ខែ និងបង្គាប់ឲ្យលោក ឈូក បណ្ឌិត សងសំណងសរុបចំនួន ៣៨ លានរៀល (៩.៥០០ ដុល្លារអាមេរិក) ដល់ជនរងគ្រោះទាំងបីនាក់។ ទាំងពិរុទ្ធជន និងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រម។

លោក ឈូក បណ្ឌិត នៅតែពុំទាន់ត្រូវបានចាប់ខ្លួននៅឡើយទេ។

**ដំណើរការសវនាការ ៖** លោក ឈូក បណ្ឌិត បានអវត្តមានជាថ្មីទៀតនៅពេលសវនាការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍។ មេធាវីការពារលោក ឈូក បណ្ឌិត ឈ្មោះ កែ វិសាល បានប្រាប់សាលាឧទ្ធរណ៍ថា កូនក្តីរបស់ខ្លួនបានដឹងអំពីសវនាការឧទ្ធរណ៍នេះ ប៉ុន្តែ ពុំបានផ្តល់ព័ត៌មានបន្ថែមទៀតអំពីកន្លែងដែលលោក ឈូក បណ្ឌិត កំពុងតែស្ថិតនៅនោះទេ។

នៅក្នុងអំឡុងពេលនៃសវនាការឧទ្ធរណ៍ ចៅក្រមបានពិនិត្យមើលលើអ្នកដែលទទួលខុសត្រូវចំពោះការបាញ់កាំភ្លើងដែលបណ្តាលឲ្យជនរងគ្រោះរបួស ជាជាងទទួលយកភស្តុតាងដាក់បន្ទុកបន្ថែមទៀត ដែល

បង្ហាញពីអំពើដោយចេតនារបស់ពិរុទ្ធជន។ សាក្សីជាង ៥០ នាក់ត្រូវបានសាលាឧទ្ធរណ៍កោះហៅ ដើម្បីផ្តល់ភស្តុតាងនៅពេលសវនាការ។ នៅខណៈដែលសាក្សីមួយចំនួនពុំបានប្រគល់ដីកាបង្វិលដើម្បីបញ្ជាក់ពីការទទួលដីកាកោះរបស់តុលាការ សាក្សីជាច្រើនផ្សេងទៀតមិនបានចូលខ្លួនដើម្បីផ្តល់សក្ខីកម្មដល់តុលាការនោះទេ។ សាក្សីដែលបានបង្ហាញខ្លួនដើម្បីផ្តល់ភស្តុតាងផ្ទាល់នៅពេលសវនាការមានតែជនរងគ្រោះ និងមន្ត្រីកងរាជអាវុធហត្ថម្នាក់ ព្រមទាំងមន្ត្រីនគរបាលមូលដ្ឋានពីរនាក់ ដែលបំពេញតួនាទីរបស់ខ្លួននៅឯ*រោងចក្រ កៅវ៉េ* នៅព្រឹកថ្ងៃដែលមានការបាញ់ប្រហារ។

នៅក្នុងសវនាការជំនុំជម្រះរបស់សាលាដំបូងខេត្តស្វាយរៀង តុលាការបានស្តាប់ភស្តុតាងរបស់អនុប្រធាននគរបាលសង្កាត់ប្រសាទ ឈ្មោះលោក ឡុង ថន។ លោក ឡុង ថន ជាសាក្សីមួយរូបដែលរំពឹងថានឹងចូលរួមសវនាការ ប៉ុន្តែខកខានមិនបានចូលបង្ហាញខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ភស្តុតាងរបស់គាត់ត្រូវបានអាននៅសាលាឧទ្ធរណ៍ ដែលបានលើកឡើងថា សាក្សីបានឃើញពិរុទ្ធជនភ្ជុងកាំភ្លើងសំដៅទៅលើកម្មករ និងបានកេះកៃកាំភ្លើង ហើយក៏បានឃើញជនរងគ្រោះទាំងនោះដួលទៅលើដី។

ទោះបីជាមេធាវីមួយរូបរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើឲ្យសាលាឧទ្ធរណ៍ពិចារណាលើការកែប្រែបទចោទប្រឆាំងនឹងពិរុទ្ធជនទៅជា "បទប៉ុនប៉ងមនុស្សឃាត" នៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយរបស់ខ្លួនយ៉ាងណាក្តី ចៅក្រមបានប្រើពេលវេលាតិចតួចលើការពិចារណាលើស្ថានភាពចេតនាប្រព្រឹត្តរបស់ពិរុទ្ធជន។

នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៣ សាលាឧទ្ធរណ៍បានចេញសាលដីកា និងបានតម្កល់សាលក្រមផ្តន្ទាទោសលោក ឈូក បណ្ឌិត ពី"បទបង្កឲ្យមានរបួសដោយអចេតនា"។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះរបស់សាលាឧទ្ធរណ៍ លោកចៅក្រម តាំង ស៊ុនឡាយ បានថ្លែងថា សម្អាងហេតុដែលក្រុមប្រឹក្សាជំនុំជម្រះសម្រេចតម្កល់សាលក្រមពី"បទបង្កឲ្យមានរបួសដោយអចេតនា" គឺដោយសារតែពិរុទ្ធជនពុំដែលស្គាល់ជនរងគ្រោះទាំងនោះទេ ហើយក៏ពុំធ្លាប់មានទំនាស់ជាមួយគ្នាពីមុនមកដែរ។ ទោះជាយ៉ាងណាក៏ដោយ ករណីនេះត្រូវបានគេជឿជាក់យ៉ាងទូលំទូលាយថា បទចោទប្រឆាំងនឹងពិរុទ្ធជនពុំឆ្លុះបញ្ចាំងអំពីភាពធ្ងន់ធ្ងរនៃអំពើបាញ់ប្រហារ ហើយភាពស្ទាក់ស្ទើរក្នុងការចោទប្រកាន់ឲ្យបានត្រឹមត្រូវ ព្រមទាំងការខកខានជាបន្តបន្ទាប់ក្នុងការចាប់ខ្លួនពិរុទ្ធជនបង្ហាញពីភាពលម្អៀងរបស់អាជ្ញាធរ នៅពេលដែលដោះស្រាយលើករណីរបស់អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងរដ្ឋាភិបាល។

វាក៏ជាប្រការសំខាន់ដូចគ្នាផងដែរសម្រាប់ចៅក្រមក្នុងការបង្ហាញពីកេរ្តិ៍ឈ្មោះដ៏ល្អក្នុងពេលបំពេញវិជ្ជាជីវៈរបស់ខ្លួននៅគ្រប់សវនាការទាំងអស់ ប្រសិនជាតុលាការចង់ឲ្យកេរ្តិ៍ឈ្មោះនេះមានភាពប្រសើរឡើងចំពោះការតាមដានរបស់អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ។ ជារឿងគួរឲ្យសោកស្តាយ ករណីដែលចៅក្រមឆ្លើយទូរសព្ទ (ចំនួន ២%) និងចាកចេញពីបន្ទប់សវនាការក្នុងពេលជំនុំជម្រះ (ចំនួន ១១%) ហាក់ដូចជាពុំមានជួយឲ្យវិជ្ជាជីវៈ ឬឯករាជ្យភាពរបស់តុលាការបានប្រសើរនោះទេ។

### តួលេខទី៩ ៖ ភាពឥតលម្អៀង និងវិជ្ជាជីវៈរបស់ចៅក្រម

| ទិន្នន័យ | មាន | | គ្មាន | |
|---|---|---|---|---|
| | ចំនួន | % | ចំនួន | % |
| តើចៅក្រមមានបង្ហាញអាកប្បកិរិយាបំភិតបំភ័យដល់ភាគីណាមួយដែរឬទេ? | ១ | ០,៥ | ២០៣ | ៩៩,៥ |
| តើចៅក្រមចាកចេញពីបន្ទប់សវនាការនៅពេលជំនុំជម្រះដែរឬទេ? | ២២ | ១១ | ១៨២ | ៩០ |
| តើចៅក្រមឆ្លើយតបទូរសព្ទនៅពេលជំនុំជម្រះដែរឬទេ? | ៤ | ២ | ២០០ | ៩៨ |

## ២.១.៨. សវនាការទាក់ទិននឹងអនីតិជន

**ប្រភពតាមច្បាប់ជាតិ និងអន្តរជាតិ ៖**

- **មាត្រា១៤(១) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ** ៖ *"សារព័ត៌មាន និងសាធារណជនអាចមិនឲ្យចូលរួមទាំងស្រុង ឬផ្នែកខ្លះនៃសវនាការ [...] នៅពេលផលប្រយោជន៍នៃជីវិតឯកជនរបស់គូភាគីតម្រូវឲ្យធ្វើដូច្នេះ [...] ប៉ុន្តែការចេញសាលក្រមទាំងអស់អំពីរឿងព្រហ្មទណ្ឌ ឬបណ្តឹងតាមផ្លូវច្បាប់ត្រូវប្រកាសជាសាធារណៈលើកលែងតែផលប្រយោជន៍អនីតិជនតម្រូវផ្សេងពីនេះ ឬនីតិវិធីរឿងក្តីនៃទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។"*
- **មាត្រា៤០(២)(ខ)(VII) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ** ៖ *"រដ្ឋភាគីត្រូវធានា ជាពិសេសថា... [កុមារទទួល] បាននូវការគោរពយ៉ាងពេញលេញនូវសិទ្ធិនៃជីវិតឯកជនរបស់កុមារ នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី។"*
- **មាត្រា១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖ *"កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ។"*
- **មាត្រា២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ** ៖ *"អនីតិជនអាយុតិចជាង ១៤ ឆ្នាំ មិនអាចត្រូវឃុំខ្លួន បណ្តោះអាសន្នទេ។ ចៅក្រមស៊ើបសួរអាចសម្រេចប្រគល់អនីតិជនឲ្យឪពុកម្តាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអ្នកអាណាព្យាបាល ត្រូវប្រគល់ទៅមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្ន រង់ចាំសេចក្តីសម្រេចរបស់តុលាការ។"*
- **មាត្រា៣៩ នៃក្រមព្រហ្មទណ្ឌ** ៖ *"អនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។"*
- **មាត្រា៤០ នៃក្រមព្រហ្មទណ្ឌ** ៖ *"វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភមានដូចតទៅ៖*

*១. ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងមានទំនុកចិត្ត។*
*២. ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។*
*៣. ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជន ដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន។*
*៤. ការប្រគល់អនីតិជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។*
*៥. ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។"*

- **មាត្រា៤០ (៤) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ៖** *"ក្រៅពីការរក្សានៅក្នុងមន្ទីរអប់រំ មានបញ្ញត្តិគ្រប់គ្រងជាច្រើនទៀត ដូចជាការថែទាំ ការតម្រែតម្រង់ និងការពិនិត្យគ្រប់គ្រង ការផ្តល់មតិទូន្មាន ការសាកល្បង ការដាក់ឲ្យរស់នៅតាមគ្រួសារ កម្មវិធីអប់រំទូទៅ និងអប់រំវិជ្ជាជីវៈ ព្រមទាំងដំណោះស្រាយផ្សេងទៀតដែលអាចប្រើប្រាស់បាន ដើម្បីធានាថាកុមារត្រូវបានទទួលការថែទាំមួយសមស្របជាមួយនឹងផាសុកភាពរបស់ខ្លួន ហើយដែលស៊ីកម្រិតគ្នានឹងស្ថានភាពរបស់កុមារផង និងទម្ងន់នៃបទល្មើសនោះផង។"*

អនីតិជនទាំងឡាយដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តបទល្មើស មានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទាំងអស់ដែលអនុវត្តចំពោះនីតិជនដែរ ព្រមទាំងទទួលបានកិច្ចការពារបន្ថែមដោយសារការពិនិត្យមើលអាយុ ភាពចាស់ទុំ និងការវិវឌ្ឍន៍ផ្នែកសតិបញ្ញា។ ក.អ.ស.ព.ន និងអនុសញ្ញាស្តីពីសិទ្ធិកុមារ ("អ.ស.ក") ដែលច្បាប់អន្តរជាតិទាំងពីរនេះចូលជាធរមាននៅកម្ពុជាកាលពីឆ្នាំ១៩៩២ ចែងពីបទប្បញ្ញត្តិជាក់លាក់មួយចំនួនសម្រាប់ការប្រព្រឹត្តចំពោះអនីតិជននៅក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងត្រូវបានគាំទ្រដោយវិធាន និងសេចក្តីណែនាំជាអន្តរជាតិមួយចំនួនទៀត។ មាត្រា ៣១ និងមាត្រា ៤៨ នៃរដ្ឋធម្មនុញ្ញបានទទួលស្គាល់យ៉ាងច្បាស់នូវ អ.ស.ក និងធានាថារដ្ឋត្រូវការពារសិទ្ធិកុមារស្របពេល ដែលក្របខ័ណ្ឌគតិយុត្តក៏បានបង្កើតបទប្បញ្ញត្តិ សម្រាប់ការអនុវត្តន៍ដាច់ដោយឡែកចំពោះអនីតិជននៅក្នុងផ្នែកសំខាន់ៗមួយចំនួនផងដែរ។

នៅក្នុងអំឡុងពេលនៃរបាយការណ៍ ក្នុងចំណោមពិរុទ្ធជនសរុបចំនួន ២៧០ នៅក្នុងសំណុំរឿងទាំងអស់ដែលបានសង្កេត ពិរុទ្ធជនចំនួន ៨ នាក់ជាអនីតិជននៅពេលប្រព្រឹត្តបទល្មើស។ ក្នុងចំណោម ៨ នាក់នេះ មានពិរុទ្ធជនជាអនីតិជនចំនួន ៦ នាក់មានអាយុចន្លោះពី ១៦ ឆ្នាំ ទៅ ១៧ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស និងមានអាយុក្រោម ១៤ ឆ្នាំម្នាក់។[40]

នៅពេលដែលបង្គាប់ ឬសម្រេចដាក់ទោសលើអនីតិជន ដែលត្រូវបានរកឃើញថាបានប្រព្រឹត្តបទល្មើសបំពាននឹងច្បាប់ព្រហ្មទណ្ឌ ចៅក្រមត្រូវពិចារណាទៅលើឧត្តមប្រយោជន៍របស់កុមារជាអាទិភាព។[41] ការអនុវត្តន៍ទោសពន្ធនាគារលើអនីតិជនត្រូវតែពិចារណាជាវិធានការចុងក្រោយបង្អស់ដែលត្រូវអនុវត្តតែក្នុង

---

[40] នៅក្នុងសំណុំរឿងដែលមានពិរុទ្ធជនអាយុក្រោម ១៤ ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ចៅក្រមបានលើកលែងបទចោទលើអនីតិជន។

[41] មាត្រា២(១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ សូមមើលផងដែរនូវគណៈកម្មាធិការស្តីពីសិទ្ធិកុមារ, *សេចក្តីអធិប្បាយទូទៅលេខ១០ ៖ សិទ្ធិកុមារនៅក្នុងយុត្តិធម៌អនីតិជន*, កថាខណ្ឌទី១០ និងទី៧១, http://bit.ly/1fbEoKP ។

ករណីពិសេសប៉ុណ្ណោះ។[42] ច្បាប់ជាតិក៏កំណត់អំពីវិធានជាជម្រើសផ្សេងទៀតក្រៅពីការអនុវត្តន៍ទោសពន្ធនាគារផងដែរ។[43] ទោះជាយ៉ាងនេះក្ដី ការព្រួយបារម្ភចម្បងគឺដោយហេតុថា ករណីចំនួន ៥ (បទឧក្រិដ្ឋចំនួន ៤ និងបទមជ្ឈិមចំនួន ១) ក្នុងចំណោមពិរុទ្ធជនជាអនីតិជនទាំង ៨ នាក់ ត្រូវបានថៅក្រមសម្រេចដាក់ទោសពន្ធនាគារ។ មានតែករណីតែ ២ ប៉ុណ្ណោះ (បទឧក្រិដ្ឋចំនួន ១ និងបទមជ្ឈិមចំនួន ១) ដែលពិរុទ្ធជនត្រូវបានសាលាឧទ្ធរណ៍លើកលែងបទចោទ និងករណី ១ ទៀត (បទឧក្រិដ្ឋ) ទោសរបស់ពិរុទ្ធជនដែលជាអនីតិជននោះត្រូវបានបន្ធូរបន្ថយ និងព្យួរការអនុវត្តន៍។ តួលេខនេះ ជាការគួរឲ្យព្រួយបារម្ភ និងការអនុវត្តន៍មានលក្ខណៈខុសប្លែកពីច្បាប់ជាតិ និងអន្តរជាតិ ដែលបញ្ញត្តថា ការដាក់ទោសពន្ធនាគារលើអនីតិជន ត្រូវតែប្រើប្រាស់ជាវិធានចុងក្រោយតែប៉ុណ្ណោះ។ វាជាការគួរឲ្យព្រួយបារម្ភដែលថា តុលាការពុំទាន់ប្រើប្រាស់ជម្រើសផ្សេងទៀតក្រៅពីការផ្ដន្ទាទោសពន្ធនាគារ ដូចដែលបានចង្អុលបង្ហាញនៅក្នុងមាត្រា ៤០ នៃក្រមព្រហ្មទណ្ឌ ដូចជា ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈដែលសម្រាប់ទទួលបន្ទុកអនីតិជន ឬ ឲ្យទៅអង្គការឯកជនដែលមាននីតិសម្បទាក្នុងការទទួលអនីតិជន ឬ ឲ្យទៅមន្ទីរពេទ្យ ឬ ស្ថាប័នឯកទេស។

ជនរងគ្រោះដែលជាអនីតិជន ឬ ភាពឯកជនរបស់ពិរុទ្ធជនដែលជាអនីតិជន អាចត្រូវបានការពារបន្ថែមទៀត តាមរយៈការប្រើប្រាស់ឧបករណ៍ផ្សេងៗ ដូចជា ប្រព័ន្ធឆ្លងឆ្លើយតាមខ្សែវីដេអូ ដែលត្រូវបានតំឡើងនៅសាលាឧទ្ធរណ៍ចាប់តាំងពីខែមករា ឆ្នាំ២០១៣។ ទោះជាយ៉ាងនេះក្ដី អ្នកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានកត់សម្គាល់ឃើញថា ប្រព័ន្ធឆ្លងឆ្លើយតាមខ្សែវីដេអូនេះពុំដែលត្រូវបានប្រើប្រាស់ឲ្យបានជោគជ័យនោះទេ។ មានករណីតែមួយគត់ ដែលតុលាការបានសម្រេចប្រើប្រាស់ប្រព័ន្ធឆ្លងឆ្លើយតាមខ្សែវីដេអូ ប៉ុន្តែការប្រើប្រាស់នេះត្រូវបានបរាជ័យទៅវិញ ដោយសារតែបញ្ហាភ្ជាប់ទំនាក់ទំនងផ្នែកបច្ចេកទេស។

នៅក្នុងអំឡុងពេលនៃការពិភាក្សាជាមួយនឹងប្រធានសាលាឧទ្ធរណ៍[44] លោកប្រធានគូសបញ្ជាក់ថា ការផ្ដន្ទាទោសលើអនីតិជន សាលាឧទ្ធរណ៍ត្រូវពិចារណាថ្លឹងថ្លែងជាខ្លាំងលើកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈនៃជនល្មើស ពីព្រោះថាសាលាឧទ្ធរណ៍អាចនឹងទទួលរងនូវសម្ពាធពីមជ្ឈដ្ឋានខាងក្រៅ អាស្រ័យហេតុនេះហើយ សាលាឧទ្ធរណ៍ត្រូវគិតគូរពីសណ្ដាប់ធ្នាប់សាធារណៈ ភាពធ្ងន់ធ្ងរនៃបទល្មើស និងការទទួលយកបានរបស់សង្គមក្នុងករណីដាក់ទោសឲ្យនៅក្រៅពន្ធនាគារ។ តែទោះជាយ៉ាងណាក៏ដោយ លោកប្រធានសង្កត់ធ្ងន់ថា សាលាឧទ្ធរណ៍បាន ហើយនិងកំពុងតែព្យាយាមយកចិត្តទុកដាក់លើការអនុវត្តន៍គោលការណ៍នៃការបង្វែរពីទោសពន្ធនាគារឲ្យអស់លទ្ធភាព ពីព្រោះថាកន្លងមកនេះ សាលាឧទ្ធរណ៍បានសហការជាមួយនឹងអង្គការយូនីសេស (UNICEF) ក្នុងការលើកកម្ពស់សិទ្ធិអនីតិជន និងការស្ដារនីតិសម្បទា។

[42] មាត្រា៣៧(ខ) នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

[43] មាត្រា២៩ និងមាត្រា៤០ នៃក្រមព្រហ្មទណ្ឌ។

[44] កិច្ចពិភាក្សារវាង ម.ស.ម.ក ជាមួយនឹងសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ឯកឧត្ដម យូ ប៊ុនឡេង ប្រធានសាលាឧទ្ធរណ៍ និងលោក ប៉ុន សាវ៉ាត់ នាយកក្រឡាបញ្ជី នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០១៤។

## ២.២. សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានគោរព

ស្របពេលដែលសកម្មភាពសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក កត់សម្គាល់នូវការអនុវត្តន៍ ដែលជាការគំរាមកំហែង និងជាការរារាំងដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដូចដែលបានរៀបរាប់ខាងលើនេះ ម.ស.ម.ក ក៏រីករាយ និងគួរឲ្យលើកទឹកចិត្តផងដែរដែលសង្កេតឃើញថា ធាតុផ្សំជាក់លាក់មួយចំនួននៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ត្រូវបានគោរព និងអនុវត្តបានយ៉ាងប្រសើរនៅសាលាឧទ្ធរណ៍។

### ២.២.១. សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី

បុគ្គលណា ដែលប្រឈមនឹងការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌគួរតែត្រូវបានផ្តល់ពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមការពារខ្លួនចំពោះបទចោទប្រកាន់ទាំងនោះ។ រយៈពេលដែលថា "គ្រប់គ្រាន់" អាស្រ័យលើប្រភេទ និងភាពស្មុគស្មាញនៃបទចោទប្រកាន់ ចំនួននៃបទចោទប្រកាន់ និងប្រភេទនៃភស្តុតាងក្នុងចំណោមកត្តាដទៃៗផ្សេងទៀត។ មធ្យោបាយចាំបាច់ក្នុងការរៀបចំការពារខ្លួនរាប់បញ្ចូលទាំងការទទួលបាននូវឯកសារ និងភស្តុតាងនានានៃសំណុំរឿង ដូច្នេះជនជាប់ចោទដឹងពីបទចោទប្រកាន់មកលើខ្លួនបានពេលលេញ ហើយជនជាប់ចោទអាចមានលទ្ធភាពផ្តល់ព័ត៌មានពេលលេញដល់មេធាវីរបស់ខ្លួន។ នៅដំណាក់កាលបណ្តឹងឧទ្ធរណ៍ ប្រការនេះក៏មានន័យថា ពិរុទ្ធជនគួរតែមានសិទ្ធិក្នុងការទទួលបាននូវសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងសេចក្តីថតចម្លងនៃសវនាការទាំងមូល ដើម្បីរៀបចំការពារក្តីរបស់ខ្លួននៅដំណាក់កាលបណ្តឹងឧទ្ធរណ៍។

សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ក្នុងការរៀបចំការពារក្តី ត្រូវបានធានាដោយមាត្រា ១៤(៣) នៃ ក.អ.ស.ព.ន[45] និងមាត្រា ៤៨ មាត្រា ៩៨ មាត្រា ១៤៥ មាត្រា ២៥៩ និងមាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅក្នុងអំឡុងពេលនៃរបាយការណ៍ ពុំមានករណីណាមួយដែលបានសង្កេត បង្ហាញថា មេធាវីការពារពិរុទ្ធជនត្រូវបានចាត់តាំងនៅចំថ្ងៃជំនុំជម្រះបណ្តឹងឧទ្ធរណ៍ ឬ ពិរុទ្ធជនលើកឡើងអំពីបញ្ហានៃពេលវេលា និងមធ្យោបាយគ្រប់គ្រាន់សម្រាប់រៀបចំការពារក្តីនោះទេ។

### ២.២.២. សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាព

សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាពនេះត្រូវបានការពារតាមមាត្រា ១៤(៣)(ឆ) នៃ ក.អ.ស.ព.ន[46] និងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ។ សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឲ្យសារភាពពីពិរុទ្ធភាពរួមបញ្ចូលការហាមឃាត់ដាច់ខាតនូវការធ្វើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ឬដាក់ទណ្ឌកម្ម។ ចំណុច

---

[45] មាត្រា១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ៖ *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាននូវពេលវេលា និងសម្ភារៈរូបវន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។"*

[46] មាត្រា១៤(៣)(ឆ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ៖ *"ក្នុងការសម្រេចសេចក្តីចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមិនត្រូវបានបង្ខិតបង្ខំឲ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។"*

នេះគឺមានន័យថា អាជ្ញាធរស៊ើបសង្កេត ឬតុលាការពុំត្រូវធ្វើការគាបសង្កត់ផ្លូវចិត្ត ឬផ្លូវកាយ ទោះដោយផ្ទាល់ ឬដោយប្រយោលទៅលើជនជាប់ចោទ ឬពិរុទ្ធជន ដើម្បីទទួលបានចម្លើយសារភាពពីពិរុទ្ធភាពនោះឡើយ។

ពុំមានករណីណាមួយដែលបានសង្កេតនៅក្នុងអំឡុងពេលនៃរបាយការណ៍ បានបង្ហាញថា ពិរុទ្ធជនត្រូវបានសួរចម្លើយដោយគ្មានមេធាវីការពារនោះទេ។ ទោះជាយ៉ាងនេះក្តី ទិន្នន័យដែលប្រមូលបាននៅតែបង្ហាញថា មានករណីចំនួន ៧ ដែលពិរុទ្ធជនលើកឡើងថា មានការប្រើប្រាស់ការគំរាមកំហែងដើម្បីបង្ខំខ្លួនឲ្យឆ្លើយសារភាពចំពោះបទល្មើសដែលបានចោទប្រកាន់ និងមានចំនួន ១១ ករណី ដែលពិរុទ្ធជនលើកឡើងថា មានការប្រើប្រាស់អំពើហិង្សា ឬ ទារុណកម្មដើម្បីបង្ខំខ្លួនឲ្យឆ្លើយសារភាពចំពោះបទល្មើសដែលបានចោទប្រកាន់មកលើខ្លួន។

ស្របពេលដែលមានភាពវិជ្ជមានដោយឃើញថា ករណីភាគច្រើនពុំមានអ្វីដែលអាចជឿបានថា សិទ្ធិរបស់ពិរុទ្ធជននៅក្នុងដំណាក់កាលសួរចម្លើយត្រូវបានប្រើប្រាស់ហិង្សា ឬទារុណកម្មនោះទេ ហើយមានតែ ១ ករណីគត់ដែលហាក់គួរឲ្យសង្ស័យ។ នៅខណៈដែលមានករណីដ៏តិចតួចប៉ុណ្ណោះ ដែលចង្អុលបង្ហាញអំពីការបង្ខិតបង្ខំលើផ្លូវចិត្ត និងផ្លូវកាយ ហេតុដូច្នេះ ជាប្រការគួរឲ្យកត់សម្គាល់ផងដែរដែលថា សាលាឧទ្ធរណ៍ត្រូវធ្វើការស៊ើបអង្កេតឲ្យបានហ្មត់ចត់។ ប្រសិនជាការអះអាងអំពីការបង្ខិតបង្ខំបែបនេះមានភស្តុតាងបង្ហាញច្បាស់បន្ទាប់ពីការស៊ើបអង្កេតពិតមែននោះ ចៅក្រមត្រូវមានកាតព្វកិច្ចតាមផ្លូវច្បាប់ក្នុងការសម្រេចច្រានចោលភស្តុតាងដែលជាការសារភាពរបៀបនេះ។ ខណៈដែលបញ្ហានេះគួរតែត្រូវបានដោះស្រាយនៅក្នុងដំណាក់កាលនៃនីតិវិធីស៊ើបសួរ ចៅក្រមជំនុំជម្រះក៏ត្រូវមានការប្រុងប្រយ័ត្នជាប់ជានិច្ច និងត្រូវធានាថា រាល់ការអះអាងអំពីការបង្ខិតបង្ខំទាំងឡាយ ដែលពុំទាន់បានដោះស្រាយនៅក្នុងដំណាក់កាលមុនពេលជំនុំជម្រះនៃសំណុំរឿងណាមួយត្រូវតែបើកការស៊ើបអង្កេតឲ្យបានល្អិតល្អន់ មុនពេលសម្រេចធ្វើការជំនុំជម្រះបន្តទៅមុខទៀត។

## ២.២.៣. ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល

ការជំនុំជម្រះទ្វេដងចំពោះបទល្មើសដដែល ឬគោលការណ៍*អាជ្ញាអស់ជំនុំ* (ពោលគឺថា "បានវិនិច្ឆ័យរួចហើយ") សំដៅលើសិទ្ធិរបស់បុគ្គលដែលត្រូវបានការពារមិនឲ្យមានការជំនុំជម្រះលើសពីម្តងចំពោះអំពើ ឬបទល្មើសដដែល។ ករណីនេះកំណត់ថាសេចក្តីសម្រេចចុងក្រោយរបស់តុលាការ ទោះបីជាការលើកលែង ឬការផ្តន្ទាទោសជនជាប់ចោទក្តី នឹងក្លាយជារបាំងហាមចំពោះការចោទប្រកាន់បន្ថែមថែមទៀតទៅលើអំពើល្មើសនោះ។ មានអត្ថប្រយោជន៍ជាច្រើនសម្រាប់ទាំងបុគ្គលជាជនជាប់ចោទ និងសង្គមជារួម ក្នុងការទទួលយកសេចក្តីសម្រេចចុងក្រោយនេះ រួមទាំងការបង្ការនូវភាពខ្ជះខ្ជាយធនធានផ្នែកច្បាប់ នៅពេលដែលសេចក្តីសម្រេចត្រូវបានធ្វើរួចរាល់ហើយនោះ។

ការហាមឃាត់ចំពោះការវិនិច្ឆ័យទោសពីរដងចំពោះបទល្មើសដដែល មានបញ្ញត្តនៅក្នុងមាត្រា ១៤ (៧) នៃ ក.អ.ស.ព.ន[47] មាត្រា ២៣ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ជាចំណុចដ៏វិជ្ជមានដែលសង្កេតឃើញថា ពុំមានករណីណាមួយដែលបានសង្កេត បានបង្ហាញថា ពិរុទ្ធជនត្រូវបានជំនុំជម្រះ និងវិនិច្ឆ័យទោសចំពោះបទល្មើសដដែលនោះទេ។

## ២.២.៤. ការហាមឃាត់ប្រឆាំងនឹងការអនុវត្តន៍អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ

គោលការណ៍ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌ គឺថាពុំមានជនណាម្នាក់ត្រូវបានរកឃើញពីពិរុទ្ធភាពនៃបទល្មើសព្រហ្មទណ្ឌចំពោះអំពើ ឬការខកខាន ដែលមិនបានបង្កើតជាបទល្មើសព្រហ្មទណ្ឌនៅពេលដែលអំពើ ឬការខកខាននោះបានកើតឡើងឡើយ។ ស្រដៀងគ្នានេះ ទោសធ្ងន់ជាងមិនអាចអនុវត្តក្រៅតែពីទោសដែលត្រូវអនុវត្តនៅពេលដែលបទល្មើសព្រហ្មទណ្ឌនោះត្រូវបានប្រព្រឹត្តឡើយ។

ការហាមឃាត់ប្រឆាំងនឹងការអនុវត្តន៍អានុភាពប្រតិសកម្មនៃច្បាប់ព្រហ្មទណ្ឌ ត្រូវបានធានាតាមរយៈ មាត្រា ១៥ នៃ ក.អ.ស.ព.ន ព្រមទាំងមាត្រា ៣ និងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌ។

ពុំមានករណីណាមួយដែលបានសង្កេត ដែលថាច្បាប់ដែលចោទប្រកាន់លើពិរុទ្ធជនណាមួយពុំមានអានុភាពអនុវត្តនៅពេលដែលបទល្មើសនោះបានកើតឡើងនោះទេ។

[47] មាត្រា១៤(៧) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ៖ *"គ្មានជនណាម្នាក់ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសាជាថ្មីឡើងវិញចំពោះបទល្មើស ដែលបានផ្តន្ទាទោសជាស្ថាពរ ឬបានលើកលែងទោសស្របតាមច្បាប់ និងនីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋនីមួយៗរួចហើយ។"*

## ៣. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ទិន្នន័យដែលប្រមូលបាននៅក្នុងអំឡុងពេលនៃការអនុវត្តន៍គម្រោង គូសបញ្ជាក់នូវតម្រូវការក្នុងការធ្វើកំណែទម្រង់លើចំណុចមួយចំនួន។ ស្របពេលដែលសាលាឧទ្ធរណ៍ ជាទូទៅប្រកាន់ខ្ជាប់នូវនីតិវិធីមួយចំនួនដែលសំដៅដល់ការធានានូវការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ បញ្ហាដែលគួរឲ្យព្រួយបារម្ភគឺលើបញ្ហាជាសារធាតុ។

ក្រៅពីការព្រួយបារម្ភជាទូទៅទាក់ទិននឹងកង្វះឯករាជ្យភាពរបស់តុលាការនៅកម្ពុជា បញ្ហាសំខាន់បំផុតដែលត្រូវដោះស្រាយជាអាទិភាព រួមមានកង្វះខាតការបិទផ្សាយការជូនដំណឹងអំពីសវនាការជំនុំជម្រះជាសាធារណៈ ចំណុចខ្វះខាតរបស់ចៅក្រមក្នុងការប្រាប់ និងពន្យល់អំពីសិទ្ធិដល់ពិរុទ្ធជន (ដែលគួរតែត្រូវរម្លឹកឡើងវិញ ទោះបីជាសាលាដំបូងទំនងជាបានធ្វើហើយក៏ដោយ) នៅមានសវនាការមួយចំនួនប្រព្រឹត្តទៅដោយពុំមានវត្តមានរបស់ពិរុទ្ធជន ហើយមានករណីជាច្រើនដែលពិរុទ្ធជនបង្ហាញខ្លួនក្នុងឯកសណ្ឋានជាអ្នកទោសពេលមានវត្តមាននៅពេលសវនាការ។ លើសពីនេះទៀត ការវិភាគទិន្នន័យបង្ហាញថា គុណភាពនៃភស្តុតាងដែលបានបង្ហាញនៅមានកម្រិតទាបនៅឡើយ ហើយនេះអាចជាហេតុផលនៃគំរាមកំហែងដល់សិទ្ធិទទួលបានការផ្តន្ទាទោសហួសពីវិមតិសង្ស័យ ព្រមទាំងបង្ហាញផងដែរថា សាលដីកាភាគច្រើនដែលបានប្រកាសនៅពេលសវនាការជំនុំជម្រះផ្ទាល់ ពុំបញ្ជាក់មាត្រាច្បាប់យោង ឬភស្តុតាងដែលបានបង្ហាញ។ បន្ថែមពីលើបញ្ហាដែលគួរឲ្យព្រួយបារម្ភទាំងនេះ បញ្ហាជាច្រើនទៀតពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន និងការអនុវត្តន៍ទោសពន្ធនាគារក៏ត្រូវតែធ្វើការដោះស្រាយដែរ។

ជារួម ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ សមត្ថភាពរបស់សាលាឧទ្ធរណ៍គួរតែត្រូវធ្វើឲ្យប្រសើរឡើង ដើម្បីអាចជួយដោះស្រាយចំនួនដ៏ច្រើននៃសំណុំរឿង ជៀសវាងការពន្យារពេលមិនចាំបាច់ និងគ្រប់គ្រងសំណុំរឿងថ្មីទៀតប្រកបដោយប្រសិទ្ធភាព និងមានការរៀបចំពេលវេលាច្បាស់លាស់។ អាស្រ័យដូចនេះ ម.ស.ម.ក សូមស្វាគមន៍ចំពោះសេចក្តីប្រកាសរបស់រដ្ឋាភិបាលដែលថា គួរតែបង្កើតសាលាឧទ្ធរណ៍បន្ថែមទៀតនៅតាមខេត្ត ហើយប្រការនេះអាចនឹងជួយដោះស្រាយបញ្ហាមួយចំនួនដែលបានលើកឡើងខាងលើ។

ក្តីបារម្ភមួយចំនួនដែលបានលើកឡើងក្នុងរបាយការណ៍នេះអាចត្រូវបានដោះស្រាយបានដោយងាយ និងឆាប់រហ័ស ដូចជា ការធ្វើឲ្យប្រសើរឡើងនូវកិច្ចសម្របសម្រួលទាក់ទិននឹងការដឹកជញ្ជូនពិរុទ្ធជនពីមណ្ឌលអប់រំកែប្រែទៅចូលរួមសវនាការ ការស្នើសាក្សីឲ្យចាកចេញពីបន្ទប់សវនាការមុនពេលសាក្សីនោះធ្វើសេចក្តីថ្លែងការណ៍ ឬនៅក្នុងបន្ទប់តែត្រូវធានាថាអាចស្វែងរកសក្ខីកម្មពិតទៅតាមរឿងហេតុនីមួយៗ ធានាថាចៅក្រមនឹងមិនចាកចេញពីបន្ទប់សវនាការ ឬសន្ទនាតាមទូរសព្ទនៅពេលដំណើរការសវនាការ ព្រមទាំងពន្យល់ប្រាប់ពីសិទ្ធិសំខាន់មួយចំនួនដល់ពិរុទ្ធជន ជាដើម។ តាមរយៈការចាត់វិធានការ ភ្លាមៗដើម្បីដោះស្រាយបញ្ហាទាំងនេះ សាលាឧទ្ធរណ៍អាចបង្កើតជាទម្លាប់ល្អ និងធ្វើជាគំរូដល់សាលាដំបូងផង ហេតុដូច្នេះប្រការនេះនឹងជះឥទ្ធិពលវិជ្ជមានលើគុណភាពជារួមនៃការគ្រប់គ្រងយុត្តិធម៌ដ៏ត្រឹមត្រូវនៅកម្ពុជា។

លើសពីនេះទៀត ដោយយោងតាមអនុសាសន៍ដែលបានដាក់ចេញខាងលើ និងជាការឆ្លើយតបទៅនឹងចំណុចខ្វះខាតមួយចំនួន ដែលបានគូសបញ្ជាក់នៅក្នុងទិន្នន័យដែលប្រមូលបាននៅក្នុងអំឡុងពេលនៃរបាយការណ៍ ម.ស.ម.ក សូមផ្តល់អនុសាសន៍បន្ថែមទៀតដូចខាងក្រោមនេះ៖

## ៣.១. អនុសាសន៍ដើម្បីធ្វើឲ្យប្រសើរឡើងនូវឯករាជ្យភាពរបស់តុលាការ

- បន្ទាប់ពីរដ្ឋសភា និងព្រឹទ្ធសភាអនុម័តច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គតុលាការ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដោយខ្វះការពិភាក្សាជាសាធារណៈ និងក្តីបារម្ភជាច្រើនរបស់សង្គមស៊ីវិលទាក់ទិននឹងការផ្តល់អំណាចដល់អង្គនីតិប្រតិបត្តិលើស្ថាប័នតុលាការ ក្រុមប្រឹក្សាធម្មនុញ្ញគួរបញ្ជូនសេចក្តីព្រាងច្បាប់ទាំងនេះទៅរដ្ឋសភាទាក់ទិននឹងបទប្បញ្ញត្តិមួយចំនួនដែលមិនស្របនឹងរដ្ឋធម្មនុញ្ញ ដើម្បីធានាថាច្បាប់ទាំងនេះស្របតាមរដ្ឋធម្មនុញ្ញ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិនានាក្នុងការធានាគោរពគោលការណ៍ឯករាជ្យភាពរបស់តុលាការ។

## ៣.២. អនុសាសន៍ទាក់ទងនឹងការពន្យល់ប្រាប់សិទ្ធិ

សាលាឧទ្ធរណ៍ត្រូវតែធានាថា របាយការណ៍សង្ខេបនៃសំណុំរឿងរបស់ប្រធានក្រុមប្រឹក្សាជំនុំជម្រះមានព័ត៌មានដូចជា ៖ បទចោទប្រកាន់ មាត្រាច្បាប់ កាលបរិច្ឆេទនិងទីកន្លែងនៃបទល្មើស ព្រមទាំងឈ្មោះភាគីដែលពាក់ព័ន្ធ។

ទម្រង់ជាបទដ្ឋានរួមមួយគួរតែត្រូវបានតាក់តែងឡើង និងអនុវត្តសម្រាប់តុលាការទាំងអស់ជាទូទៅ។ ក្រឡាបញ្ជីគួរអានទម្រង់នេះ ដែលមានកំណត់នូវព័ត៌មានសំខាន់ៗដូចខាងក្រោម ៖

- បទល្មើសដែលចោទប្រកាន់លើជនជាប់ចោទ ឬពិរុទ្ធជន និងបញ្ញត្តិច្បាប់ពាក់ព័ន្ធទាំងឡាយ
- កាលបរិច្ឆេទ ពេលវេលា និងទីកន្លែងដែលបទល្មើសនោះបានកើតឡើង និងភាគីដែលពាក់ព័ន្ធនានា
- សិទ្ធិសំខាន់ៗរបស់ជនជាប់ចោទ ឬពិរុទ្ធជននៅពេលជំនុំជម្រះ រួមជាមួយនឹងការពន្យល់ដែលមានបទដ្ឋានច្បាស់លាស់ និងល្អិតល្អន់អំពីសិទ្ធិទាំងនោះ។

